BMI0063

**សម្ភាសន៍ជាមួយឈ្មោះ ង៉ែត សារឿន ហៅ ង៉ែត ធីម**

**ភេទប្រុស អាយុ៥៥ឆ្នាំ**

**មុខងារនៅសម័យខ្មែរក្រហមៈ កងពិសេសមន្ទីរ៨៧០**

**មុខងារបច្ចុប្បន្នៈ "ក្រុមប្រឹក្សាឃុំម៉ាឡៃ"**

**ស្រុកកំណើតនៅភូមិក្តីចាស់ ឃុំអន្លង់ជ័យ ស្រុកអន្លង់ជ័យ ខេត្តកំពត**

**សព្វថ្ងៃរស់នៅភូមិដំបូកវិល ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ**

**ថ្ងៃទី២០ ខែតុលា ឆ្នាំ២០១០**

**សម្ភាសន៍ដោយៈ ហ៊ុន សុធានី**

**០១:២៩:២៨**

**៣៧ទំព័រ**

ធានី : ថ្ងៃទី២០ ខែតុលា ឆ្នាំ២០១០ ។ ពួកខ្ញុំមកពីខាងមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ហើយខ្ញុំចុះមកនេះ ខ្ញុំចង់សាកសួរពីប្រវត្តិរបស់ពូ ហេតុអីបានពូមកដល់ស្រុកម៉ាឡៃ ហើយប្រវត្តិរឿងរ៉ាវទាំងអស់នេះទុកឲ្យក្មេងៗបានសិក្សាស្រាវជ្រាវផ្សេងៗ ។ តើពូអនុញ្ញាតិឲ្យខ្ញុំថតជាសម្លេងក៏ដូចជារូបថតអីចឹងបានទេ?

សារឿន : ខ្ញុំអនុញ្ញាតិថតបាន ។ និយាយពីប្រវត្តិរូបខ្ញុំមូលហេតុអីបានខ្ញុំមកដល់ស្រុកម៉ាឡៃ ។ ខ្ញុំអនុញ្ញាតិថតជាសម្លេងបាន ។

ធានី : ពូឈ្មោះអីដែរ?

សារឿន : ខ្ញុំបាទ! ឈ្មោះ ង៉ែត សារឿន ។

ធានី : ពូមានឈ្មោះហៅក្រៅទេ?

សារឿន : ឈ្មោះដើម ឈ្មោះ ធីម ។

ធានី : ធីម មួយមាត់ទេ?

សារឿន : ង៉ែត ធីម ដដែល ត្រកូលង៉ែត ។

ធានី : ឆ្នាំនឹងពូអាយុប៉ុន្មាន?

សារឿន : ឆ្នាំនឹងខ្ញុំអាយុ៥៥ឆ្នាំ ។

ធានី : ពូមានស្រុកកំណើតនៅណាដែរ?

សារឿន : ស្រុកកំណើតនៅភូមិក្តីចាស់ ឃុំអន្លង់ជ័យ ស្រុកឈូក ខេត្តកំពត ។

ធានី ៖ សព្វថ្ងៃរស់នៅណាដែរ?

សារឿន ៖ សព្វថ្ងៃរស់នៅភូមិដំបូកវិល ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។

ធានី ៖ ឪពុកពូឈ្មោះអីគេ?

សារឿន ៖ ឈ្មោះ ង៉ែត ងួន ។

ធានី ៖ គាត់នៅរស់ទេ?

សារឿន ៖ ស្លាប់ ។

ធានី ៖ ស្លាប់ពេលណា?

សារឿន ៖ ស្លាប់តាំងពីជំនាន់សង្គមរាស្ត្រនិយម ។

ធានី ៖ គាត់ឈឺ?

សារឿន ៖ គាត់មានជម្ងឺ ។

ធានី ៖ ម្តាយឈ្មោះអី?

សារឿន ៖ ម្តាយឈ្មោះ អ៊ុច ជឹម ។

ធានី ៖ គាត់នៅរស់ទេ?

សារឿន ៖ ស្លាប់អស់ហើយ ។

ធានី ៖ ស្លាប់ពេលណា?

សារឿន ៖ សម័យរដ្ឋកម្ពុជា ឆ្នាំ៨៤ ។

ធានី ៖ ដោយសារអីដែរ?

សារឿន ៖ ជម្ងឺក្អក ។

ធានី ៖ ពូមានបងប្អូនប៉ុន្មាននាក់?

សារឿន ៖ ខ្ញុំមានបងប្អូន៤ ស្រី១ ។

ធានី ៖ ស្រី១ ប្រុស៣?

សារឿន ៖ បាទ!

ធានី ៖ នៅរស់ទាំងអស់?

សារឿន ៖ ស្លាប់អស់មួយ នៅសល់៣ ពិការជើង២ ។

ធានី ៖ ស្លាប់ស្រី ឬប្រុស?

សារឿន ៖ ស្លាប់ប្រុស ។ ខ្ញុំប្រុស២នាក់នឹងពិការជើង ។

ធានី ៖ ស្រីមួយគាត់នៅ?

សារឿន ៖ នៅ សព្វថ្ងៃគាត់នៅព្រះវិហារ អត់អីទេ ។

ធានី ៖ នៅយើងនេះទេ ពូដែលពិការជើង?

សារឿន ៖ នៅអន្លង់វែង នៅឥឡូវគេដាក់ភូមិសាមគ្គី ក្តីចាស់នឹង ។

ធានី ៖ មួយពិការជើងនៅស្រុកកំណើត មួយទៀតទៅនៅម៉ាឡៃ មួយនៅព្រះវិហារ?

សារឿន ៖ ព្រះវិហារ ។

ធានី ៖ ពូរៀនសូត្របានថ្នាក់ទីប៉ុន្មានដែរ?

សារឿន ៖ បាទ! ខ្ញុំរៀនសូត្របានថ្នាក់ទី៧ ។

ធានី ៖ កាលពីមុន?

សារឿន ៖ បាទ! ទី៧ពីសង្គមចាស់ ។

ធានី ៖ ពូអាចជួយរៀបរាប់ពីដំបូងមក ម៉េចបានពូបានមកដល់ស្រុកម៉ាឡៃ?

សារឿន ៖ យើងកុំនិយាយវែងពេក យើងនិយាយពី៧៩មកហើយ ។

ធានី ៖ ស្រេចចិត្តពូ ពី៧៩មកយើងអត់ដឹងដើមទង គេឆ្ងល់ដែរ ។

សារឿន ៖ បាទ! ខ្ញុំសូមជម្រាបជូនថា នៅឆ្នាំ១៩៧២ មានចលនាបដិវត្តយើងដើរឃោសនាចំពោះយុវជន អន្ទិត ឬក៏ព្រះសង្ឃដើម្បីចូលរួមចលនាតស៊ូរំដោះ(ណាសិវ្យជំនាន់នោះខ្ញុំចាំមិនបានអស់ទេ ។ ក្រោយមកខ្ញុំក៏ចូលធ្វើបដិវត្តន៍ នៅឆ្នាំ១៩៧២ ខែ២ ។ ខ្ញុំចូលនៅសង្កាត់ភ្នំកុងស្រុកអន្លង់វែង ខ្ញុំធ្វើជានារសាសង្កាត់ ។ ដល់ឆ្នាំ១៩៧៣ ខ្ញុំចូលធ្វើជាយោធាស្រុក ខ្ញុំមានឋានន្តរសក្តិ បើយើងនិយាយពីជំនាន់នោះមេក្រុម ។ ដល់ឆ្នាំ១៩៧៣ ខែកក្កដា ខ្ញុំបានឡើងជាមេបញ្ជាការកងអនុសេនាតូច ប្រចាំកងទ័ពស្រុកអន្លង់វែងនឹងតែម្តង ។ ដល់ឆ្នាំ១៩៧៤ គេបញ្ជូនមកវៃនៅទីក្រុងតាកែវ ពេលនោះខ្ញុំមានរបួសជើងខាងឆ្វេង ជើងដែលខ្ញុំដាច់នឹង របួសដោយគ្រាប់សុវ៉ាន់ធីណៃ គ្រាប់M78 ។ ហើយខ្ញុំរក្សាព្យាបាល នៅឆ្នាំ១៩៧៥ ខ្ញុំត្រូវដកទៅធ្វើបុណ្យ១៧មេសា នៅក្នុងស្រុកដដែល ។ ក្រោយមកខ្ញុំក៏មកនៅឈរជើងនៅក្នុងអង្គភាពដដែល លុះឆ្នាំ១៩៧៦ ។ យើងនិយាយភាសាកាលនោះ ខ្ញុំសុំអនុញ្ញាតនិយាយភាសាសម័យនោះតិច ពេលនោះមេបញ្ជាការ ឬអង្គការបក្សតំរូវឲ្យខ្ញុំមករដ្ឋធានីភ្នំពេញ ។ ខ្ញុំមកនៅរដ្ឋធានីភ្នំពេញ ខ្ញុំធ្វើជាកងចល័តសម្រាប់ដើរបោសសំអាតក្រុងដែលវាអាក្រក់នៅមន្ទីរ៨៧០ ។ កាលនោះខ្ញុំជាអ្នកបោសសំអាតក្រុងរហូតដល់ឆ្នាំ៧៩តែម្តង ។ ដល់ឆ្នាំ៧៩ ថ្ងៃ៧មករា ខ្ញុំត្រូវភៀសខ្លួនចេញពីរដ្ឋធានីភ្នំពេញមកភាគខាងលិចនេះឯង ខ្ញុំអត់ដឹងទិសដៅគេត្រូវទៅណាដែរ ។ កាលនោះដោយខ្ញុំគិតថា ខ្ញុំប្រហែលជាមានជីវិតថ្មីមួយទៀត ខ្ញុំត្រូវតែទៅនៅក្នុងព្រៃដើម្បីធ្វើការតស៊ូរំដោះយកប្រទេសជាតិខ្ញុំវិញ ។ សម័យនោះ ដោយសារយើងជឿលើអង្គការបក្សត្រឹមត្រូវ ខ្ញុំក៏មកដល់ស្រុកម៉ាឡៃ ។

មុនដំបូងខ្ញុំអត់មាននៅម៉ាឡៃនេះទេ ខ្ញុំនៅខេត្តបាត់ដំបងនោះ ។ ខ្ញុំនៅក្នុងក្រុងប៉ៃលិន ធ្វើជាយោធា ។ ខ្ញុំនិយយារំលងបន្តិចហើយ សុំអធ្យាស្រ័យ ចេញពីភ្នំពេញ ខ្ញុំមកឈរជើងនៅស្រុកខត្តុងក្នុងព្រៃ នៅម្តុំអមលាំង ត្រពាំងជងនេះ ក្នុងនាមលាក់ការណ៍សំងាត់ជាកងចល័តដដែល គឺគ្មានមេគ្មានកើយទេ ដោយសារចេះមកតាមគ្នា ។ រហូតដុំជាដុំគ្នា បានជាអង្គភាពទៅឈរជើងនៅជិតភ្នំស្អីនៅខេត្តកំពង់ស្ពឺ ធ្វើចលនាតស៊ូរំដោះនៅនឹង ។ កាលនោះ ខ្ញុំនៅវរៈ១២៤ ។ កាលនោះបង១គាត់ស្លាប់អស់ហើយ ដោយសារគាត់មានជម្ងឺ គាត់ចាស់ៗ ។ ហើយដល់ខ្ញុំចេះចល័តតៗមកនៅរហូតឈរជើងនៅប៉ៃលិនបានតែ៦ខែទេ ខ្ញុំចល័តមកដល់ស្រុកម៉ាឡៃ ។ កាលនោះខ្ញុំមានឋានន្តរសក្តិហៅមេកងតូចកងធំ ។ លុះដល់មកខ្ញុំនៅក្នុងម៉ាឡៃ ខ្ញុំមិនមានធ្វើអីទេ ។ ប៉ុន្តែ ខ្ញុំមានមេបញ្ជាការខ្ញុំម្នាក់ គាត់ឈ្មោះ បងផន គាត់យកទៅនៅជាមួយដោយសំអាងទៅលើការចេះដឹងរបស់ខ្ញុំតិចតួច ។ គាត់យកទៅធ្វើជាអ្នកបកសារទូរលេខសម្រាប់អង្គភាពកងទ័ពនឹង ។ ដល់មេខ្ញុំគាត់ផ្ទុះមីនឆ្នាំ៨៤ គាត់ផ្ទុះមីនស្លាប់ ។ ខ្ញុំ គាត់ឲ្យឡើងជាមេបញ្ជាការ-គ ។ កាលនោះ យើងមានកម្លាំងមិនច្រើនទេ មានតែ៣០-៤០នាក់ គេគិតម៉ា-គហើយ ។ ខ្ញុំចេះតែឈរជើងទៅ ខ្ញុំនៅកំលោះនៅឡើយអត់ទាន់មានគ្រួសារទេ ។ លុះដល់អីចឹងមក ខ្ញុំក៏ត្រឡប់មកក្រោយធ្វើបុណ្យមេរួច ខ្ញុំក៏មានគ្រួសារសព្វថ្ងៃនឹង ។ ខ្ញុំត្រឡប់ទៅវិញនៅឆ្នាំ៩១ ខ្ញុំធ្វើការជាមួយUNTAKនៅក្នុងស្រុកមង្គលបូរី បានរយៈពេលប៉ុន្មានខែនឹង គេបោះឆ្នោត ។ ៩២ ៩៣គេបោះឆ្នោត ។ ខ្ញុំត្រឡប់ចេញមកស្រុកវិញ ដោយយើងកាលនោះខ្ញុំអត់ដឹងរឿងនយោបាយរបស់គេ ខ្ញុំអត់និយាយទេ ខ្ញុំអត់ដឹង ។ ខ្ញុំក៏ត្រឡប់មកនៅព្រៃវិញ ។ ដល់ថ្នាក់លើឃើញការងារយើងល្អ ការងារសកម្មក្នុងការងារ ខ្ញុំក៏កាន់ជាអនុបញ្ជាការវរសេនាតូច គេហៅមេបញ្ជាការរងនោះរហូតមកដល់សព្វថ្ងៃ រហូតដល់ឆ្នាំយើងសមាហរណ៍កម្ម ខ្ញុំជាអនុសេនីយ៍ទោ ផ្នែកនាយការិយាល័យទី១ ការិយាល័យដំបូងរបស់ទាហានក្នុងវរសេនាធំលេខ៦៨ កងពលលេខ២១រហូតមកដល់បច្ចុប្បន្ននេះនៅតែធ្វើការនៅកន្លែងឃុំសង្កាត់ដដែល ។ ខ្ញុំអស់ត្រឹមនឹង ខ្ញុំអត់បាននិយាយខ្ញុំពិការ ។

ធានី : និយាយតិចពូ?

សារឿន : អីចឹងរង្វង់ក្រចកថយក្រោយបន្តិច ខ្ញុំអត់បានត្រៀមទុកកន្លែងខ្ញុំពិការ ។ ដល់ខ្ញុំមានឋានន្តរសក្តិពាក់សក្តិនៅឆ្នាំ១៩៩៨ ។ យើងសមាហរណ៍កម្មមិនឆ្នាំ១៩៩៦ ចូលជាមួយរាជរដ្ឋាភិបាល ។

ធានី : ៩៦ ៩៧?

សារឿន ៖ ៩៦ ថ្ងៃទី១៥ ។

ធានី ៖ ខែប៉ុន្មាន?

សារឿន ៖ ខែមិថុនា អឺ!ខែសីហា ។

ធានី ៖ ៩៧ ឬ៩៦?

សារឿន ៖ អត់ទេ ៩៦ៗពេញច្បាស់ណាស់ ។ ខ្លាចបង ធី ភួន ហៅចៀម គាត់ចាំមិនបាន តែខ្ញុំចាំបាន ។ ពេលនឹងខ្ញុំគេឲ្យខ្ញុំយកកងទ័ពពីមុខមកទាំងអស់ ដើម្បីយើងត្រួតពិនិត្យអាវុធយើងបញ្ជូរអាវុធទាំងអស់ ។ អត់ទាន់ដូរខោអាវទេ យើងនៅស្លៀកខោអាវចិនដដែល ។ អីចឹងពេលនឹងខ្ញុំមកឆ្នាំ៩៧ មានការតែងតាំងក្រឹត្យដើម្បីបញ្ចេញថានាយទាយម្នាក់នេះ គឺធ្វើការផ្នែកនេះៗ ។ ពេលនោះ ខ្ញុំអត់ទាន់ពិការជើងទេ ខ្ញុំនៅកាន់នាយការិយាល័យទី១របស់វរសេនាធំនឹងដដែល ក្នុងកងពលលេខ៤៥០កាលនោះ ។ រហូតមកដល់ឆ្នាំ៩៨ ពាក់សក្តិរួចហើយ ខ្ញុំទៅធ្វើស្រែខាងកើតដែលក្មួយស្រីTelហៅខ្ញុំអំបាញ់មិញនឹង ខ្ញុំនឹកឃើញស្រណោះកូនខ្លាចភ្លៀងសាចខ្ទមស្រែចុះទៅកាប់កូនឈើ២ដើមមិនបានកាប់ឈើ ក៏ជាន់មីនដំបងរបស់ក-៥នឹង ផ្ទុះមីនដាច់ជើងឆ្វេងតែម្តង ។ ហើយខ្ញុំក៏មិនទាន់វ៉ៃតម្លៃទេ ដោយមេបញ្ជាការយើងមិនទាន់ដឹងវ៉ៃតម្លៃទៅយើងជាយ៉ាងម៉េច ខ្ញុំអត់ទាន់បានវ៉ៃតម្លៃជាជនពិការទេ ។ ខ្ញុំឡើងទៅធ្វើការនៅភ្នំពេញចំនួនម៉ាដង ខ្ញុំត្រឡប់មកវិញក៏ខ្ញុំអត់ទាន់កាត់រំសាយដែរ ដោយពេលនោះ ខ្ញុំមិននិយាយថាយ៉ាងម៉េចទេ តែខ្ញុំចង់ជម្រាបថាជំនាញកាលណាយើងរៀនបានហើយមិនងាយនឹងបំបាត់ទៅវិញ កាលណាយើងចេះរួចហើយ យើងខ្វះធនធានមនុស្សសម័យនោះ យើងត្រូវជ្រើសរកមនុស្សដែលអាចធ្វើការបាន ។ អីចឹងមេបញ្ជាការក៏កំណត់ឲ្យខ្ញុំជានាយអង់បេរហូត ។

ធានី ៖ នាយអង់បេម៉េច?

សារឿន ៖ អង់បេភាសាបារាំង ខ្មែរយើងជានាយការិយាល័យទី១ ។ ខ្ញុំធ្វើរហូតមកដល់ឆ្នាំ១៩៩៩ ជិតចូល២០០០ ខ្ញុំក៏ដាក់ឈ្មោះទៅបោះឆ្នោតធ្វើការរដ្ឋបាលឃុំសង្កាត់ ខ្ញុំជាប់ជាក្រុមប្រឹក្សាឃុំសង្កាត់រហូតមកដល់សព្វថ្ងៃវាមានចំនួន២អាណត្តិហើយ ដែលខ្ញុំធ្វើការក្នុងការងារនឹង ។ អីចឹងខ្ញុំអត់មានអីជម្រាបជូនក្មួយទេ ឆាកជីវិតរបស់ខ្ញុំបើនិយាយពីកំសត់ៗហួសពេក ពេលខ្ញុំពិការជើង ខ្ញុំអត់មានប្រាក់ទេ ខ្ញុំមានតែប្រាក់៥០០បាតក្នុងហោប៉ៅ ។ ពេលនោះបានលោកមេបញ្ជាការលោកជួយៗព្យាបាល ។ យើងមិនមែន ពិការនឹងយើងប្រយុទ្ធវ៉ៃជាមួយសត្រូវទេ យើងពិការក្នុងការងាររកស៊ីហូបចុករបស់ខ្លួនឯង ។ អីចឹងខ្ញុំគិតថាតំបន់ដែលមានមីនរហូតមកដល់បច្ចុប្បន្នក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាលនឹង យើងបានស៊ីម៉ាក់មក

ប្រោសសំអាត ។ កន្លែងក្មួយស្រីអង្គុយសុទ្ធតែតំបន់ក-៥ ហើយនឹងមីន ។ នេះកន្លែងវាល
ស្រែតំបន់ឯដលក្មួយស្រីក្រលេកឃើញដំបងខ្សែលួសទី៥ ។

ធានី ៖ សុទ្ធតែមានរបងគេទាំងអស់?

សារឿន ៖ បាទ! ដំបងលួសទាំងអស់ ។

ធានី ៖ ដំបងលួសធ្វើអី?

សារឿន ៖ បើសម្រាសកុំឲ្យខ្មែរក្រហមចូលទៅក្នុងស្រុកខ្មែរបង្កសកម្មភាពបាន ។

ធានី ៖ មុននឹងពូថានៅឆ្នាំ១៩៧២ ។ ពូធ្វើនារសា តាមរយៈអ្នកណាគេហៅទៅធ្វើ?

សារឿន ៖ បងស្រីខ្ញុំបាទផ្ទាល់ បងស្រីងែត ៣ង ។ ដោយកាលនឹង គេមានកូនប្រុសផ្ទះខ្ញុំមាន៣នាក់
កុំឲ្យគេដកទាន់ ខ្ញុំអាណិតប្អូនៗទុកឲ្យសិក្សាសិន គេមិនទាន់បិទសាលាស្រុកខ្ញុំ ។ សាលានឹង
បង្រៀនដោយលោកគ្រូ យើងគ្រូកាលនឹងមិនមានកម្រិតខ្ពស់ទេ បើថាគ្រូធំៗបែកគ្នាអស់
តាំងពី៧០ ។ ទុកឲ្យប្អូនសិក្សាឲ្យបានយ៉ាងហោចណាស់ក៏បានត្រឹមខ្ញុំសុំនិយាយថ្នាក់ថ្មីយ៉ាង
ហោចណាស់ឲ្យបានត្រឹមថ្នាក់ទី៤សម័យសព្វថ្ងៃ ។ តាមពិតប្អូនខ្ញុំរៀនបានត្រឹមថ្នាក់ទី៤មែន
ខ្ញុំមកធ្វើនឹងដោយសារតាមរយៈបងស្រី ។

ធានី ៖ បងស្រីធ្វើដែរ?

សារឿន ៖ បងស្រីធ្វើមុន ។

ធានី ៖ ហើយគាត់ធ្វើអីគេ?

សារឿន ៖ បងស្រីខ្ញុំកាលនឹងគាត់ធ្វើប្រធាននារីឃុំ ។

ធានី ៖ ប្រធាននារីឃុំ?

សារឿន ៖ ភ្នំកុង ។

ធានី ៖ ដល់ពេលពូធ្វើ?

សារឿន ៖ នារសាឃុំ ។

ធានី ៖ ប្រធានឃុំភ្នំកុងអ្នកណាគេ?

សារឿន ៖ អូ! ខ្ញុំចាំមិនបានទេ គាត់ស្លាប់អស់ទៅហើយ វាយូរពេកក្មួយស្រីយូរណាស់ ។ គាត់ស្លាប់
អស់ហើយ ។

ធានី ៖ ចុះគណៈស្រុកសម័យនឹង?

សារឿន ៖ គណៈស្រុកពូញ៉ែម នៅព្រះវិហារសព្វថ្ងៃ ។ ប្រពន្ធគាត់យាយថែម ។

ធានី ៖ បន្ទាប់មកទៀត ពេលពូឡើងធ្វើមេបញ្ជាការកងវរសេនាតូចនឹង តាញ៉ែមនឹងគាត់នៅគ្រប់
គ្រងដែរ?

សារឿន ៖ អត់ទេ គាត់នៅគណៈស្រុកដែរ យើងបែកគ្នា ។ ខ្ញុំធ្វើយោធាផ្សេង អត់ទាក់ទងគ្នាទេ ។

ធានី ៖ ពូយោធាស្រុក ខុសពី?

សារឿន ៖ គណៈស្រុកលោកគ្រប់គ្រងដដែល ប៉ុន្តែមានមេបញ្ជាការមួយទៀត មេបញ្ជាការកងទ័ពស្រុកនឹង ។

ធានី ៖ អ្នកណាគេ?

សារឿន ៖ កាលនឹងឈ្មោះបងប៉ាវ ស្លាប់ហើយនៅស្រុកត្រាំកក់ ។ ប៉ាវ ហ៊ិន ស្អី១ច្រើនគ្នាដែលចាំមិនអស់ ។ ហ៊ិនប្រហែលជាអាចនៅរស់ ព្រោះគ្នាកំបុតដៃនៅឃុំគូស ។ ហ៊ិន គឹនអីបែបស្លាប់អស់ហើយ ចាំគេមិនបានបែបស្លាប់អស់ហើយ ។

ធានី ៖ ពូវិនៅតាកែវនឹង ពូនៅធ្វើមេបញ្ជាការកងអនុសេនាតូចដដែល?

សារឿន ៖ ខ្ញុំអត់ទេ ខ្ញុំមេក្រុម ។

ធានី ៖ ពូថាមេបញ្ជាការកងតូច?

សារឿន ៖ មេបញ្ជាការកងតូច១ កាលនឹងខ្ញុំមេបញ្ជាការកងតូច ខ្ញុំនៅនឹងវិនៅជិតគេហៅវត្តជើងចាប ។

ធានី ៖ ហើយអ្នកណាគេអ្នកធ្វើ ប្រធានពូតានឹងដដែល?

សារឿន ៖ អត់ទេ ។

ធានី ៖ អ្នកផ្សេងទៀត?

សារឿន ៖ ប្រធានកងទ័ពស្រុកគេនោះមិនដឹងឈ្មោះអីទេ ខ្ញុំចាំប្រធានអនុសេនាធំប៉ុន្មាននាក់ ហ៊ិន គឹមហើយនឹងប៉ាវ១ខ្វាក់មួយចំហៀង ។ ស្លាប់ហើយ ចាស់១ខ្ញុំដឹងថាស្លាប់ហើយ ខ្ញុំទៅស្រុកខ្ញុំ រកគាត់អត់ឃើញ ។

ធានី ៖ ស្រុកកំណើតគាត់ជាមួយពូដែរ?

សារឿន ៖ ជិត១គ្នា ទៅរកគាត់អត់ឃើញសួរគេថាស្លាប់ហើយ បងប៉ាវ ។ ពេលនឹងក្រោមការគ្រប់គ្រងគណៈតំបន់ឈ្មោះបងសោម និងបងមុត ។

ធានី ៖ ស្អីគេសោម?

សារឿន ៖ អត់ស្គាល់ត្រកូល ។

ធានី ៖ ចុះមុត?

សារឿន ៖ អត់ដឹងស្អីមុត ប៉ុន្តែស្លាប់អស់ហើយ ។ ពួកអតីតគ្រូបង្រៀន ។

ធានី ៖ ពេលពូទៅវិនៅតាកែវហើយ ឆ្នាំ៧៥រួចពីវិទៅណា?

សារឿន ៖ រួចពីវិខ្ញុំមកធ្វើបុណ្យជ័យជំនះ១៧មេសា ។

ធានី ៖ នៅណា?

សារឿន ៖ នៅវត្តប្រភ្នំ ស្រុកអន្លង់វែង ដដែល ។

ធានី ៖ ធ្វើនៅនឹង?

សារឿន ៖ បាទ!

ធានី ៖ បន្ទាប់មកទៀតនៅឆ្នាំ១៩៧៦ បានពូមកបោសសំអាត?

សារឿន ៖ បាទ! បោសសំអាតទីក្រុងភ្នំពេញ ។

ធានី ៖ ពូនៅអន្លង់វែងបានប៉ុន្មាន បានពូទៅ?

សារឿន ៖ អត់មានបាននៅអន្លង់វែងយូរទេ គឺឆ្នាំ៧៦ខ្ញុំឈរជើងបានឈរបានរយៈចន្លោះពេលនឹង គេក៏ជម្រើសៗរកមនុស្សដែលអត់ពាក់ព័ន្ធ ។ យើងប្រើភាសាកាលនឹង បើកាលណាពាក់ព័ន្ធគេមិនអាចយកមករដ្ឋធានីភ្នំពេញបានទេ ។ ហើយខ្ញុំអត់មានពាក់ព័ន្ធទេ អ្នកមូលដ្ឋាន ខ្ញុំក៏អត់មានពាកព័ន្ធនឹងបងប្អូនធ្វើទាហាន ធ្វើគិញ ធ្វើគយ គឺស្អាត ។

ធានី ៖ គេហៅមក?

សារឿន ៖ ហៅមកជម្រើសបាន៣០នាក់គត់ ។ គេបម្រុងយកទៅណាយើងអត់ដឹង ។ ហើយក៏គេឡើងយកមកទុកនៅមន្ទីរក-៧នឹង ។ ហើយគេឲ្យដើរបោសសំអាតក្រុង ។

ធានី ៖ មិនមែនឆ្នាំ៧៧ ក្រោយហើយ?

សារឿន ៖ ហ៊ឺ! ៧៦ឡើងមកគេរៀបចំយើង ។ ឲ្យយើងចូលជាមួយគេ ដើម្បីគេសំលឹងមើលយើង ព្រោះយើងយុវវ័យកាលនឹង គេត្រូវការយុវវ័យនឹងដើម្បីសិក្សាអីផ្សេងៗវាបានច្រើនក្មេង កាលនឹងខ្ញុំនៅក្មេងមែនទែនទើប២០ អាច១៨-១៩ កំពុងពេញស្អាត ។ គេមើលកម្លាំងយើងថាយើងអាចធ្វើអីបានខ្លះ ។ ពួកខ្ញុំក្រៅពីការងារសំណង់ និងបោសសំអាតខ្ញុំអត់ចេះ ។ ខ្ញុំទៅបោសសំអាតបរមរាជវាំង ខ្ញុំកាត់ស្មៅអីព្រះមហាក្សត្រ ។

ធានី ៖ កាលពេលពូរើសមក អ្នកណាគេរើសពូមក?

សារឿន ៖ ខ្ញុំ ប្រធានតំបន់ បងសោម ។ ប្រធានតំបន់គាត់រើសមកឲ្យសម្រាកកន្លែងគាត់ម៉ាយប់ បានគេឲ្យមកភ្នំពេញ ។

ធានី ៖ ពេលមកដំបូង គេអត់ប្រាប់ថាម៉េច?

សារឿន ៖ គាត់ប្រាប់ថាពួកឯងអញ្ជូនទៅភ្នំពេញហើយ ។ ហើយរើសសុទ្ធតែមេបញ្ជាការអនុសេនាតូចទាំងអស់ អត់មានពាក់ព័ន្ធ ។

ធានី ៖ ប៉ុន្មាននាក់ ចាំ?

សារឿន ៖ ៣០នាក់ ។

ធានី ៖ ស្គាល់ឈ្មោះទេ?

សារឿន ៖ អូ! ក្មួយស្រីអើយស្លាប់អស់ហើយ នៅតែខ្ញុំពិការជើងទៀត ។

ធានី ៖ ពូថាឆ្នាំវ៉ៃនៅតាកែវ ពិការជើងឆ្វេង?

សារឿន ៖ អត់ទាន់ពិការ ខ្ញុំត្រូវរបួសជើងនេះ ។

ធានី ៖ របួសជើងឆ្វេង តែអត់ពិការទេ?

សារឿន ៖ អត់ពិការទេ ខ្ញុំត្រូវរបួសនេះ ខ្ញុំសម្រាកពេទ្យនៅ... ខ្ញុំអត់ទាន់ផ្ដេចជើងណា ផ្ដាច់ជើង៩៧ ៩៨នេះ ។

ធានី ៖ ពូត្រូវរបួសជើងឆ្វេងអត់ទាន់អីទេ តែព្យាបាលយើងមកធ្វើការធម្មតា?

សារឿន ៖ បាទ!

ធានី ៖ ដល់៧៦ពូមកក-៧ធ្វើការ?

សារឿន ៖ បាទ!

ធានី ៖ ពូទៅបោសសំអាតកន្លែងណាខ្លះទៅ?

សារឿន ៖ ខ្ញុំបោសសំអាតតាំងពីដូចថាផ្ទះណាបាក់បែកម៉ាដួរបឹងកេងកង ទួលទំពូង ។

ធានី ៖ គេឲ្យបោសសំអាតធ្វើអី?

សារឿន ៖ បោសសំអាតក្រុង កុំឲ្យមានក្រដាស ឬស្អីសភាពអួរអាប់តាមដងវិថីល្អៗ ដើម្បីយើងដូនសំរាមយកមកចោល ដើម្បីរៀបចំផ្ទះសម្បែងឡើងវិញ ឲ្យល្អតាមទីដងវិថីផ្សេងៗ ។ ហើយយើងកាលនឹងអត់មានឡានដឹកសំរាមទេ មានតែឡានសេអ៊ីមសេរបស់ទាហាន ខ្ញុំក៏នៅក្នុងអង្គភាពរបស់ទាហានដែរ តែខ្ញុំទាហានបោសសំអាតសំរាមតាមទីក្រុង ។ មិនមែនខ្ញុំជាកម្មករ ដូចយើងសព្វថ្ងៃថាជាកម្មករ តែជំនាន់នោះមានតែកម្មករបោសជាជួរៗ តែខ្ញុំមិនទាន់ទៅជាកងទ័ពទេ ។ ដូចខ្ញុំជម្រាបជូនក្មួយស្រី ថាគេនៅមើលយើង ខ្ញុំអត់ទាន់រហូតដល់វៀតណាមចូលស្រុក ។

ធានី ៖ ពេលពូទៅបោសសំអាតនឹង ពេលពូចូលមកដល់ដំបូងប្រជាជនថ្មីរើចេញឬនៅ?

សារឿន ៖ អូ! ចេញតាំងពី៧៥ ខ្ញុំមក៧៦ ។

ធានី ៖ ពូទៅបោសសំអាតនៅផ្ទះគេធ្វើអី?

សារឿន ៖ ទិសដៅយើងចង់សំអាតក្រុង ដើម្បីរៀបចំជួរផ្ទះឲ្យស្អាត ព្រោះកម្មវិធីផ្សេងទៀតពូអត់ដឹងដែរ ។ គ្រាន់ថាយើងបោសសំអាត គ្រាន់ថាខ្ញុំដឹងខ្លះៗដែរតាមរយៈនឹងក្រោយមកមានភ្ញៀវបរទេសទៅ ។

ធានី ៖ ទៅគេឯកន្លែងពូបោសសំអាតនឹង?

សារឿន ៖ អត់ទេ តាមផ្លូវជនវិថីរបស់យើង កាលណាយើងអត់ស្អាត គេមើលរបស់យើងប្រទេសយើងមានស្ថានទូតស្ថានអីទៅច្រើនដែរ ម៉្លេះហើយកុំឲ្យគេថាយើងចេះចុះតាមខ្ញុំយល់ទស្សនៈរបស់ខ្ញុំ ។ ដូចជាផ្លូវជនវិថីវិមានឯករាជ្យ កាលយើងអត់បោសសំអាត ក៏វាអត់ល្អមើលដែរ យប់ឡើង ព្រលឹមឡើងដឹងមាន ។

ធានី ៖ បោសរាល់ថ្ងៃ?

សារឿន ៖ បោសរាល់ថ្ងៃ ដើម្បីសំអាតទីធ្លាដូចថាកន្លែងណា តំបន់ណាដែលយើងមើលទាក់ភ្នែក ភ្ញៀវទេសចរណ៍គេមកក្នុងស្រុក ។ កាលនឹងខ្ញុំមានភ្ញៀវប៉ុន្មានប្រទេស ខ្ញុំចាំមិនបានទេ ។ តែដឹងថាមានយូហ្គោស្លាវី កូរ៉េ ចិន ជប៉ុនមកក្រោយគេ ហើយថៃឡង់នេះក៏មានទៅដែរ ស្ថានទូតយើង ។ ហើយវៀតណាម ខ្ញុំមិនបាច់រាប់ទេ ព្រោះវៀតណាមខ្ញុំភ្លេចដែរ វៀតណាមមានយូរទៅហើយ ។

ធានី ៖ វៀតណាមមានដែរ សម័យខ្មែរក្រហម?

សារឿន ៖ មាន១ វៀតណាមនៅជិតស្ថានទូតអាមេរិចសព្វថ្ងៃ វៀតណាមនៅជិតម៉ុំកាឡុក នៅជិតបឹងកេងកងនឹងឯង ។ បើយើងអត់បោសសំអាតទេនោះ មិនដឹងជាក្រុងយើងអាក្រក់ប៉ុនណាទេ តែមានកន្លែងខ្លះដែរពូដឹង គេអត់ឲ្យពួកពូបោសពូអត់ដឹងទេ ។ ពូបោសតាមផ្លូវជនវិថីពេទ្យចិន ជិតផ្សារឡាក់គី ម៉ាផ្លូវផ្សារថ្មី ផ្លូវបូរីកីឡា ស្តារអូរឡាំពិច សុទ្ធតែកន្លែងពូធ្វើការ ។

ធានី ៖ បោសសំអាតរហូត?

សារឿន ៖ បោសសំអាត កាលណាយើងមានសំរាម យើងត្រូវតែបោស ។

ធានី ៖ សំរាមមកពីណាខ្លះ?

សារឿន ៖ សំរាមមកពីមែកក្ងោកអី ស្លឹកឈើ តែក្រដាសស្នាមតាមផ្លូវជនវិថីមួយ១គេសុទ្ធតែចាក់សោរផ្ទះគេអត់ឲ្យរើរុះរបស់គេទេ របស់របររបស់នៅក្នុងនឹងប៉ុន្មាន យើងអត់មានប៉ះពាល់អីរបស់គេទេ ។

ធានី ៖ យើងបោសតែតាមផ្លូវ?

សារឿន ៖ បាទ! បោសតែតាមផ្លូវ ។ ផ្ទះផ្លូវជនវិថីមួយ១គ្មានអី ដូចថាកន្លែងនេះការិយាល័យក្រដាសយើងឃើញបោស ។

ធានី ៖ ពេលពូនៅបោសសំអាតនៅនឹង មានអ្នកផ្សេងទេ ដែលបោសសំអាតដូចពូ ក្រុមពូ?

សារឿន ៖ ខ្ញុំមាន៦០នាក់ ។

ធានី ៖ ទាំងអស់គ្នាបោសភ្នំពេញនឹង?

សារឿន ៖ អត់ទេ តែម៉ាអគ្គភាពហ្នឹង អ្នកបោស ៦០នាក់ ។

ធានី ៖ បោសកន្លែងណាខ្លះ?

សារឿន ៖ បោសតែដងវិថីផ្លូវប្រជាធិបតេយ្យ បោសត្រឹមតែវិមានរដ្ឋសភាចាស់ ។ ហើយនឹងមកដល់វិមានឯករាជ្យ មកដល់ស្ពានទូតអាមេរិចនឹងផ្លូវពួកខ្ញុំបោសហើយ ។ តែត្រឹមនឹងទេ ហើយក្រៅពីនឹងទៀតគ្មានទេ ។ ហើយទៅដល់យើងមហោស្រពសុទ្ធតែកន្លែងខ្ញុំបោសសំអាត ។ មហោស្រពជិតការបួយ៉ាណាសព្វថ្ងៃ គេដាក់រទេះភ្លើងក្មេងលេង ។ តែប៉ុននឹងបរិវេណខ្ញុំគ្រប់គ្រង ហើយរាំងសម្តេចសីហនុនឹង ។

ធានី ៖ ពូបោសសំអាតនៅក្នុងនឹងដែរ?

សារឿន ៖ បោសកាត់ស្មៅកាត់អី ហើយក្រោយមកបានគេដូរដោយក្រសួងការបរទេសចូលបោសវិញ

ធានី ៖ កាលដំបូងមន្ទីរក-៧?

សារឿន ៖ បាទ! មន្ទីរក-៧អ្នកបោសសំអាត ក្រោយមកបានគេឲ្យយកក្រសួងការបរទេសទៅបោសសំអាតដោយយកអ្នកចាស់ៗទៅប្រចាំ ។

ធានី ៖ យកចាស់ៗទៅវិញ ក្មេងៗចេញ?

សារឿន ៖ ក្មេងៗចេញហើយ គេប្រើធ្វើការកើត ចាស់ៗគ្រាន់កាត់ស្មៅកាត់កើត ។

ធានី ៖ ក-៧ អ្នកណាគេគ្រប់គ្រងនៅនឹង?

សារឿន ៖ ក-៧ ប្រធានធំជាងគេបងព្រំ ។

ធានី ៖ ចុះអ៊ំខុសរ្យាហ៍ទៅនឹងទេ?

សារឿន ៖ អត់ ។

ធានី ៖ អត់ដែលឃើញ?

សារឿន ៖ អត់ដែលឃើញ ។

ធានី ៖ កាលពេលពូស្នាក់នៅណា នៅក-៧នឹង?

សារឿន ៖ ខ្ញុំនៅក-៧នឹង ។ផ្ទះពួកខ្ញុំឲ្យដេក មុនដំបូងស្នាក់នៅបូរីកីឡាផ្ទះរាវែងធំ ផ្ទះចាស់យើងប៉ុន្មានជាន់សព្វថ្ងៃគេធ្វើសាលារៀនហើយ ។

ធានី ៖ ដំបូងពូស្នាក់នៅបូរីកីឡា បន្ទាប់មកទៀតបានទៅ?

សារឿន ៖ ទៅនៅកន្លែងក-៧នឹងទៅបោសសំអាតបណ្តោយ ខ្ញុំឡើងពីស្រុកយើងដំបូង ។ ប្រធានក-៧នឹង ឈ្មោះបងព្រំ អ្នកគ្រប់គ្រង ។

ធានី ៖ គ្រប់គ្រងខាងសំអាតនឹង?

សារឿន ៖ អត់ទេ គ្រប់គ្រងធំ ប្រធានមន្ទីរក-៧ ។ អ្នកគ្រប់គ្រងខ្ញុំងាប់បាត់ហើយ ។

ធានី ៖ អ្នកគ្រប់គ្រងពូឈ្មោះអីគេ នៅក-៧មានប៉ុន្មានផ្នែក?

សារឿន : នេះតាមអនុសេនាតូចទេ គឺមេខ្ញុំគាត់ស្លាប់បាត់ហើយ គាត់នៅ១០៦ ផ្ទះគាត់ ស្លាប់ដោយជម្ងឺលើសឈាម ជាតិ ផល មេរបស់ខ្ញុំ ។

ធានី : មេបោសសំអាត?

សារឿន : បាទ! មេក្រុមអនុសេនាតូច ។ ពេលនឹងខ្ញុំអត់មានតួនាទីតំណែងអីទេ ខ្ញុំមកភ្នំពេញកូនក្រុមសុទ្ធសាធ ។ ហើយបងជាតិនោះគេឲ្យធ្វើរង តែម៉ែទេ នៅកំពង់ចាមគាត់អ្នកគ្រប់គ្រងធំជាងគេ ។

ធានី : ម៉ែស្រី ប្រុស?

សារឿន : ប្រុស សព្វថ្ងៃ មិនដឹងជាគាត់ស្លាប់ ឬរស់នៅស្រុកបាធាយខេត្តកំពង់ចាម ។ គាត់ស្លាប់ហើយតាមមើលចាស់ដែរ បែប៦០ជាង បើមិនមានជម្ងឺ ក៏អីផ្សេង ប៉ុនដឹងថាគាត់អត់មកតាមខ្ញុំ គាត់ទៅផ្ទះគាត់មានតែជាតិនឹងឯង ដែលគាត់ដឹកនាំកម្លាំងមក ។ ឥឡូវគាត់ស្លាប់ហើយដួលលើសឈាម ។

ធានី : ពូស្គាល់តាលីមទេ?

សារឿន : បងលីមគាត់ មាឌសៗ បងលីមគាត់ជនជាតិស្គាល់តើ ។

ធានី : គាត់នៅមន្ទីរ៨៧០ ?

សារឿន : បាទ! ស្គាល់ ។

ធានី : ក្រែងគាត់ធំជាងគាត់នឹង?

សារឿន : ធំៗ បងព្រាំប្រធានផ្នែកៗ ។

ធានី : ព្រាំនឹងប្រធានផ្នែករបស់ពូ?

សារឿន : អត់ទេ គាត់ប្រធានមន្ទីរនឹង ។

ធានី : ចុះតាលីម?

សារឿន : តាលីមធំ គាត់គ្រប់គ្រងលើ ។

ធានី : ក្រែងគាត់នៅមន្ទីរ៨៧០ ?

សារឿន : នៅហ្នឹងដែរ តែគាត់ធំលើនឹងទៀត ។

ធានី : គាត់ងារជាអី?

សារឿន : ខ្ញុំអត់ដឹងរឿងពេលនោះយើងអត់ដឹងអីទាំងអស់ ដឹងថាមេយើងប៉ុនណាប៉ុននោះ ។

ធានី : មេយើងជាប្រធានផ្នែក ឬក៏ប្រធានមន្ទីរ៨៧០ ?

សារឿន : មេខ្ញុំមិនមែនប្រធានមន្ទីរ៨៧០ទេ គាត់ប្រធានមន្ទីរខ្ញុំតែម្តង ។

ធានី : ប្រធានមន្ទីរបោសសំអាត?

សារឿន : បាទៗ មន្ទីរវាមានច្រើន អាមួយទៀតទូលាយធំណាស់អានឹងមន្ទីរធំ អានេះម៉ាសាខាយើងមាន២-៣កងអនុសេនាតូចនឹង ។

ធានី : ពេលពូរត់ចេញពីភ្នំពេញមក អត់មានអ្នកណាដឹកនាំពូមក ឬមួយក៏យ៉ាងម៉េច?

សារឿន : អត់មាន ។

ធានី : គេប្រាប់ថាម៉េចបានចេញពីមន្ទីរ?

សារឿន : អត់មានអ្នកណាគេថាអី ពេលនោះយើងមានការបារម្ភខ្លះដែរ ព្រោះយើងអត់ដឹងរឿងអីស្រាប់តែឮសូរកាំភ្លើងប្រាវទៅហើយ បើយើងអត់រត់ខ្លាចគ្រោះថ្នាក់ អត់មានអ្នកណាឃោសនាអីផង ព្រោះយើងឮសូរកាំភ្លើប្រាវៗ បើមិនគេចខ្លាចគេបាញ់ចំយើង ។

ធានី : ពូដល់កំពង់ស្ពឺចង្រ្កងវរៈ២៧០?

សារឿន : អានឹងខ្ញុំចូលមកអង្គភាពជាមួយគេ ។

ធានី : ជាមួយអ្នកណាគេ?

សារឿន : ជាមួយបងហៀង មេបញ្ជាការវរសេនាធំ មិនដឹងទៅណាផងសព្វថ្ងៃនឹង បើបាត់គ្នា បែកគ្នារហូតសព្វថ្ងៃ ។

ធានី : ហើយពូនៅប៉ៃលិននៅ៦ខែធ្វើអីគេទៅ?

សារឿន : ខ្ញុំយោធាធម្មតា យោធានៅជាប់ព្រំដែន យើងនៅដូចថាវៀតណាមមកកិកៗយើងបេះចល័តខ្លួនមកទៀត ។

ធានី : ពូថាអ្នកបកសារទូរលេខ?

សារឿន : ទូរលេខអត់ទាន់ដល់ទេ ។

ធានី : នៅខាងណាវិញ?

សារឿន : ទូរលេខដល់ខ្ញុំមកនៅម៉ាខ្សែនេះ ។

ធានី : នៅទូរលេខនឹងធ្វើអីខ្លះទៅ?

សារឿន : បកសារទូរលេខដូចថាដំណឹងសមរភូមិមុខ សមរភូមិក្រោយ ។

ធានី : យើងមានទូរលេខប្រើដែរ?

សារឿន : មានទូរលេខចិន ។

ធានី : ដូចថាទាក់ទងពីណាទៅណា?

សារឿន : ទាក់ទងតាមដូចថាទូរលេខនឹងមានមេបញ្ជាការកងពល ដូចបងសុខភាពនឹងកន្លែងគាត់មានទូរលេខ ហើយខ្ញុំនៅជួរមុខៗត្រូវជូនសារមកគាត់ថាខ្ញុំខ្វះទឹកដឹក យើងសរសេរជាលេខទាំង

អស់ ហើយបកជាអក្សរ ។ ខ្ញុំបកសារថាគោរពជូនលោកមេបញ្ជាការ ខ្ញុំខ្វះស្បៀងយើង សរសេរជាលេខដើម្បីទាក់ទងគ្នា ។ ខ្ញុំមករៀនបកសារ ខ្ញុំមិនមែនអ្នកវ៉ៃទេ ។

ធានី ៖ ពូអ្នកបកសារទូរលេខនឹងតាំងពីឆ្នាំណាមក ពូចេះទូរលេខនឹង?

សារឿន ៖ ឆ្នាំ៨៥ ។

ធានី ៖ ៨៥ពូរៀនបកសារ?

សារឿន ៖ ខ្ញុំរៀនៗរយៈពេល៣ខែ ។

ធានី ៖ ខាងណាមកបង្រៀនដែរ?

សារឿន ៖ គ្នាឯងនឹង ។

ធានី ៖ គាត់ចេះ?

សារឿន ៖ គ្រូៗគាត់រៀនតគ្នា ។

ធានី ៖ អ្នកណាគេអ្នកបង្រៀនពូ?

សារឿន ៖ បង្រៀនបកនឹង កាលនឹងហេង ញ៉ នៅធ្វើការការិយាល័យស្រុក ។

ធានី ៖ ដល់ពេលបកហើយ បកឲ្យតាជន?

សារឿន ៖ បកឲ្យតាជន ។

ធានី ៖ ពូនៅជួរមុខ គាត់នៅជួរក្រោយ?

សារឿន ៖ បាទ! អ៊ីភាពនៅក្រោយ ខ្ញុំនៅមុខ ។

ធានី ៖ ពេលតាមជនស្លាប់ទៅពូឡើងជំនួស?

សារឿន ៖ ខ្ញុំគាត់ឲ្យធ្វើមេបញ្ជាការ-គជំនួសកន្លែងនឹងវាអត់មាន ម៉ាក្រុមនឹងមានខ្ញុំនឹងហើយចាស់ទុំជាងគេ ។ មិនមែនចាស់ទុំអីទេ ចាស់ទុំផ្លូវចិត្ត ចាស់ទុំផ្នែកបើយើងនិយាយសរុបមកវិញ គឺថាយើងមានចំណេះដឹងលើគេបន្តិច ។

ធានី ៖ បន្ទាប់មកទៀតធ្វើអីគេ ៨៤?

សារឿន ៖ ខ្ញុំនៅនឹងរហូតៗដល់ឆ្នាំ ។

ធានី ៖ វ៉ៃគ្នារហូត?

សារឿន ៖ បាទ!វ៉ៃគ្នារហូត ។

ធានី ៖ ជាមួយវៀតណាម?

សារឿន ៖ បាទ!

ធានី ៖ អត់បានទៅនៅជំរុំទេ?

សារឿន ៖ អត់ទេ ។

ធានី ៖ ពួកអ៊ីថា ៨៥ នឹងវៀតណាមវ៉ៃមកច្រើន ហើយយើងជម្លៀសអ្នកនៅនឹងឲ្យទៅ?

សារឿន ៖ ជម្លៀសនឹងខ្ញុំកាលនោះ ខ្ញុំនៅក្នុងនៅឡើយ កាលនោះខ្ញុំជាប់នៅស្រុកអូរជ្រៅខេត្តយើងពីដើមនៅខេត្តបាត់ដំបង ខ្ញុំនៅជាប់ក្នុង អត់មានបានមកនឹងគេ ។

ធានី ៖ ម៉េចអ៊ីចឹងវិញ?

សារឿន ៖ ចុះគេវៀតណាមកាត់ផ្លូវនេះដាច់អស់ហើយ ខ្ញុំមានឆ្លងមករួចណា ។

ធានី ៖ ពូកាលនឹងវ៉ៃមកដល់អូរជ្រៅវិញ?

សារឿន ៖ ខ្ញុំនៅម្តុំនឹងតំបន់ព្រៃ យើងពិបាកវាស់ស្ទង់ណាស់សព្វថ្ងៃសុទ្ធតែភូមិ ខ្ញុំនៅឈរជើងម្តុំនឹងគេហៅស្រះក្រោះៗសព្វថ្ងៃវាលស្រែហើយ ។ ភូមិតាំងទីលំនៅថ្មីនៅក្នុងស្រុកម៉ាឡៃនឹង ។ នៅកណ្តាលព្រៃសុទ្ធ ខត្តុង្គសុទ្ធ ។ ហើយខ្ញុំទៅធ្វើការជាមួយប្រជាពលរដ្ឋសំណេះសំណាលដើម្បីទិញអាហារមកហូបខ្លួនឯង ។

ធានី ៖ ពេលនឹងពូកំពុងទាក់ទងដើម្បីយកអាហារ នៅអូរជ្រៅនឹង?

សារឿន ៖ បាទ! យកអាហារ យកអង្ករឲ្យប្រជាពលរដ្ឋនឹងលួចដឹករទេះយកមកលក់ឲ្យយើងមក ។

ធានី ៖ វៀតណាមវ៉ៃចូលមក ផ្តាច់ផ្លូវក៏អត់បានមកម៉ាឡៃ?

សារឿន ៖ មកយើងម៉ាឡៃនេះទេ ។

ធានី ៖ ខ្ញុំពីដើមមិនមែននៅកន្លែងនេះទេ ខ្ញុំនៅទួលពង្រ ខ្លាងាប់នោះ តែអង្គភាពខ្ញុំវានៅនឹងដល់ក្រោយមកយើងចាំខ្ញុំជម្រាប់ក្នុយមួយគន្លាក់ ។ កាលខ្ញុំនៅកំលោះនៅនឹងទាំងអស់អង្គភាពខ្ញុំ ។

សារឿន ៖ នៅទួលពង្រនឹង?

ធានី ៖ កន្លែងដើមចាន់គិរីផ្លូវកាច់ៗជិតប៉ុស្តិ៍រដ្ឋបាលសព្វថ្ងៃកន្លែងពួកខ្ញុំហើយ ។ ហើយបានក្រោយមក ដោយសារគេឲ្យខ្ញុំចុះទៅឆ្នាំ៨៤នឹង ឲ្យខ្ញុំចុះទៅកាលនឹងខែមករា ។ ខ្ញុំចុះទៅដើម្បីយកស្បៀង យកគ្រាប់រំសេវមួយចំនួនទៅឲ្យមេបញ្ជាការដែលឈរជើងនៅភូមិក្បាលខ្មោច ឃុំសំរោង ស្រុកអូរជ្រៅនោះ ព្រោះមេបញ្ជាការលោកឈរជើងនៅនឹង ។

សារឿន ៖ ភូមិក្បាលខ្មោចក្រែងនៅបាត់ដំបង?

ធានី ៖ អត់ទេ ភូមិក្បាលខ្មោចនៅស្រុកអូរជ្រៅ ខ្ញុំយកសម្ភារៈនៅនឹងហើយ ខ្ញុំក៏ៗ ហើយយើងអ្នកបកសារទូរលេខ គេប្តូរផ្លាស់គ្នា ។ ហើយក្រោយមកទៀតនោះ ក៏យើងចេះសំរុកឡើងមក ព្រោះទាក់ទងខាងលើថា ឲ្យសមមិត្តដកទ័ពនឹងចេញមកដើម្បីយើងឆ្លងផ្លាស់ប្តូរគ្នាមកធ្វើការ ។ ខ្ញុំក៏ត្រូវឆ្លងកាត់ កាលនឹងគេហៅនងអៀងៗភាសាសៀមទេ ខ្មែរយើងហៅថាអាអូរមួយជាប់អូរខែដននេះ ខ្ញុំឆ្លងកាត់តំបន់នឹងដើម្បីឡើងមកទៅប្រទេសថៃនៅជំរុំ៨៥ ។

សារឿន ៖ ចុះពូឆ្លងពីស្រុកអូរជ្រៅទៅវិញ?

ធានី ៖ បាទ! ឆ្លងពីស្រុកអូរជ្រៅទៅវិញ?

សារឿន ៖ បាទ! ឆ្លងពីស្រុកអូរជ្រៅទៅវិញ ។

ធានី ៖ តាជននឹងគាត់ស្លាប់ហើយ បានពូមក ឬមួយ?

សារឿន ៖ អត់ទេ អ៊ំជន អត់ទាន់ស្លាប់ទេ ពេលនឹងគាត់នៅមេបញ្ជាការនៅឡើយ ដល់ឆ្នាំ៨៤នឹង ដែលមេបញ្ជាការអត់ឲ្យចុះមកវិញ ចុះមកវិញចុះនៅសាឡុងខងភាសាថៃ ខ្មែរយើងដឹង ហៅអីខ្ញុំហៅតាមភាសាថៃ តំបន់នឹងនៅជិតភ្នំថៃដែរ នៅឈរជើងនៅជិតខ្វាផាប់ដដែល ដើម្បីធ្វើការដោះមីនដោះអី ដើម្បីបោសសំអាតរបងក-៥ដែលវៀតណាមដកអស់ហើយ ។

ធានី ៖ របងក-៥ម៉េច?

សារឿន ៖ របងក-៥គេធ្វើរាំងដែលខ្ញុំជម្រាបក្មួយស្រី សុទ្ធតែចំរូងហើយនឹងរបងលួស ។

ធានី ៖ ម៉េចបានគេហៅក-៥?

សារឿន ៖ មិនដឹងដែរ ព្រោះក-៥ខាងក្នុងគេហៅមកធ្វើរបង គេកែណ្ឌពលរដ្ឋនៅស្រុកយើងនឹងមក ធ្វើរបងដើម្បីរាំងកុំកម្លាំងតស៊ូនឹងចូលទៅក្នុងនឹងបាន ។ ហើយទៅដាក់មនុស្សម៉េចដាប់របង លួស គេកាត់អស់ទៅហើយ ។ តំបន់នេះឆ្លងកាត់អត់បានដល់វៀតណាមនៅត្រង់នេះ ខ្ញុំមិន ដែលឆ្លងទេ ខ្ញុំឆ្លងនៅម៉ាជួរខ្វាផាប់ហើយនឹងនងអៀន ដែលខ្ញុំនិយាយមិញ យើងសព្វថ្ងៃគេ ហៅទំនប់កាច់ខែជននឹង ។ ឆ្លងតាមតំបន់នឹងយើងវៀនៗតាមព្រៃរបោះៗយើងអាចឆ្លងកាត់ បាន ។

ធានី ៖ នៅនេះគឺអត់អាច?

សារឿន ៖ អត់អាចម៉ង ព្រោះយើងឆ្លងទៅត្រង់នេះ គឺមានផ្លូវចល័តពីដើមផ្លូវឡានដឹកអីវ៉ាន់នៅកងទ័ព ជួរមុខគេវៀតណាម ។ ហើយយើងមិនអាចឆ្លងកាត់ផ្លូវគេបានទេ តែឆ្លងកាត់គេឃើញដាន ជើងគេតាមប្រមាញ់យើង ។ យើងទាមទាររបស់ ជនាន់នឹងទាហានរបស់ រវាស ។ ហើយ ខ្ញុំជាអ្នកបកសារ ខ្ញុំស្ពាយតែឯកសារខ្ញុំអត់មានអាវុធនឹងគេទេ ។

ធានី ៖ អត់មានរត់មុនគេៗវៃ?

សារឿន ៖ អត់ ខ្ញុំនៅក្រោយគេបំផុត ។ បាទ!អត់មានមុខទេ ធម្មតាអ្នកអីចឹងៗគេកងទ័ពជួរមុខគេវៃ បញ្ចូលគេភាវមីនភាវអីយើងដើរតាមគេទៅ ស្រួលណាស់ខ្ញុំ មិនយាប់ ។

ធានី ៖ ពូនៅ៨៥អត់?

សារឿន ៖ ខ្ញុំនៅពេលនៅជុំវិ៨៥ ។

ធានី ៖ នៅបានប៉ុន្មាន?

សារឿន ៖ នៅឡើងកូនមួយ មានលេងណា នៅឡើងបានប្រពន្ធរៀបការនៅនោះឯង ។

ធានី ៖ ពូរៀបគ្រួសារនៅ៨៥?

សារឿន ៖ បាទ! រៀបនៅ៨៥ ។

ធានី ៖ នៅឆ្នាំប៉ុន្មាន?

សារឿន ៖ នៅឆ្នាំ៨៥ដែរ នៅខែ៧ខ្ញុំរៀបគ្រួសារ ។

ធានី ៖ គ្រួសារពូឈ្មោះអី?

សារឿន ៖ ឈ្មោះ កែវ សារឿង ។ មិនមែននារីដឹកជញ្ជូនទេ កូនប្រជាពលរដ្ឋសុទ្ធសាធ ប៉ុន្តែអ្នកត្រឹមត្រូវ ។ កាលនឹងពូគិតបេះ ពូគិតថាបើសិនជាពូមរណភាពទៅ អស់និស្ស័យផ្លូវបុណ្យ ពូគិតថាយ៉ាងហោចណាស់ក៏មានមនុស្សម្នាក់សម្រាប់តពូជរបស់ពូដើម្បីទៅប្រាប់យាយតាវានៅឯស្រុកកាលនឹងម្តាយខ្ញុំនៅរស់ ។ មិនមែននៅរស់ទៅ ខ្ញុំអត់ដឹងដំណឹងដែរ ដល់ខ្ញុំចុះទៅស្រុកបានដឹង ខ្ញុំចុះទៅបេសកកម្មនៅម៉ុំប៉ោយអន្លុរ តាមរយៈបងស្រីខ្ញុំនៅភូមិសំរោងគាត់ប្រាប់ ។ ខ្ញុំមានបងប្អូននៅបាត់ដំបងច្រើនណាស់គាត់ប្រាប់ថា *“អន្ទិតអើយ ម្តាយអន្ទិតស្លាប់ហើយ” “ចុះញោមស្លាប់ដោយសារជម្ងឺអី” “អឺ!ម្តាយឯងក្អកធ្លាក់ឈាម”* ។ គាត់មករកខ្ញុំរកដើម្បីទាមទារយកខ្ញុំទៅវិញ ។

ធានី ៖ គាត់មករកពូដល់កន្លែងនេះដែរ?

សារឿន ៖ បាទ! មករកអត់ប៉ះកន្លែងខ្ញុំ គាត់ទៅរកដល់ជំរុំនងចាន់ ជំរុំអូរបីជាន់ ម៉េចប៉ះខ្ញុំ ខ្ញុំនៅខ្មែរក្រហម គាត់នៅខាងនោះប៉ារ៉ាអត់ប៉ះខ្ញុំទេ ។ គាត់ត្រឡប់មកវិញមក គាត់មានជម្ងឺក្អកធ្លាប់ឈាមរហូតដល់គាត់អស់បុណ្យពីផ្លូវលោក ។

ធានី ៖ ពូនៅ៨៥ដល់ពេលណាបានពូត្រឡប់មកម៉ាឡៃវិញ?

សារឿន ៖ ៨៩ យើងត្រឡប់មកឈរជើងនៅនឹង(ម៉ាឡៃ) ខ្ញុំអត់បាននៅនឹងទេ ខ្ញុំនៅជួរមុខនៅឡើយ

ធានី ៖ ជួរមុខម៉េច?

សារឿន ៖ ខ្ញុំនៅទាហាននៅមុខ គ្រួសារខ្ញុំគេដឹកមក ។

ធានី ៖ ពូមកមុនឬគាត់មកមុន?

សារឿន ៖ គ្រួសារខ្ញុំមកគេដឹកមកដាក់នៅផ្ទះខ្ញុំនៅសព្វថ្ងៃ គេដឹកមកខ្លួនគេ ។

ធានី ៖ តែពូមកមុន?

សារឿន ៖ ខ្ញុំមកមុនមីង ៗគាត់នៅក្រោយទេ គាត់មានទំនង់កូនកណ្តាល សព្វថ្ងៃកូននឹងអាយុ២០-២១ជាប់បាក់ឌុបហើយ ។

ធានី ៖ ពូមក៨៩ ឬមីងមក៨៩?

សារឿន ៖ មីងមក៨៩ ។

ធានី ៖ ពូមកប៉ុន្មាន?

សារឿន ៖ ក្នុង៨៩ដូចគ្នា តែពូនៅមុខ ។

ធានី ៖ មកមុមប៉ុន្មានដែរ?

សារឿន ៖ ពូមកមុនយូរហើយ តាំងពីខែកក្កដា ពូនៅឈរជើងធ្វើជាមេបញ្ជាការវរសេនាតូច ។ គេមិនអាចផ្លាស់ប្តូរយើងទេ សុខចិត្តប្រពន្ធកូនគេដឹកមើលឲ្យយើង ។

ធានី ៖ ពូវិម៉ុជួរមុខ វិម៉ុណាទៅ?

សារឿន ៖ វិភូមិសំរោងហៅអង្រែ ខ្ញុំនិយាយឲ្យខ្ញីសមរភូមិក្តោបហៅថាសមរភូមិស៊ីសាផុន ។

ធានី ៖ នៅវិម៉ុសំរោង នៅក្នុងខេត្តបាត់ដំបង?

សារឿន ៖ កាលនោះនៅខេត្តបាត់ដំបងទាំងអស់ បន្ទាយមានជ័យ ១៩៨៨ ។

ធានី ៖ ស្ថិតនៅបាត់ដំបង?

សារឿន ៖ ស្រុកនឹងបាត់ដំបងទាំងអស់ ។

ធានី ៖ ពូដឹងថាម៉ាឡៃស្ថិតនៅក្នុងស្រុកមួយណានៃខេត្តបាត់ដំបង?

សារឿន ៖ ម៉ាឡៃស្ថិតនៅស្រុកអូរជ្រៅ ។ បើយើងនិយាយពីឃុំសង្កាត់ខ្ញុំអត់ទាន់ច្បាស់ តែខ្ញុំទៅគិតនឹងទៅអានឹងបើយើងនិយាយតាមត្រង់ក្នុងស្រុកដែលខ្ញុំនៅនេះក្នុងឃុំនិមិត្ត ។

ធានី ៖ ឃុំនិមិត្ត ស្រុកអូរជ្រៅ?

សារឿន ៖ បាទ! ហ្នឹងភូមិនឹងឃុំនឹងធំណាស់ ដីសុទ្ធតែព្រៃ អាកន្លែងនេះខ្ញុំជម្រាបជូនក្មួយស្រីព្រៃសុទ្ធសាធតែម្តង ។ សូម្បីយើងសម្រាកនៅអង្រឹងសុទ្ធតែភ្លីបារត ហើយចាញ់ណាស់ស្រុកនេះ ។

ធានី ៖ កាលពេលពូមកដំបូងវាព្រៃក្រាស់ខ្លាំង?

សារឿន ៖ ព្រៃក្រាស់ណាស់ សុទ្ធតែយើងត្រូសត្រាយអីកាំបិតយើង ដូចកាំបិតខ្ញុំកាន់មកកាំបិតទាហាន

ធានី ៖ តាំងពីជំនាន់ណា?

សារឿន ៖ ជំនាន់អានឹងកាំបិតអាមេរិចកាំង តាំងពីឆ្នាំណាពូមិនដឹងដែរ ប៉ុនពូបានប្រើកាំបិតនឹង ដោយសារអានេះមិនមែនកាំបិតគេបើហ្នឹងទេ កាំបិតក្រោយទៀតទេ ដែលពូរើសបាន ។ កាំបិតហ្នឹងស្រាប់ត្រូសត្រាយកន្លែងដេករបស់ទាហានមេទិញកាំបិតត្រាយព្រៃឲ្យដេក ចងកៅស៊ូធ្វើរោងក្រងស្បូវក្រងអី ។ ពូអ្នកសិក្សាដែរ ពូអត់ចេះក្រងស្បូវទេ ពឹងលើមិត្តនារីគាត់ចេះ ។ ពូចេះធ្វើរបៀបជនជាតិយើងវិប្ញស្សីគៀបធ្វើកុំឲ្យទឹក ។ ចេះតែនៅទៅកំលោះផង យើងអត់សូវគិតអីទេ ។ ពេលខ្ញុំមានកូនបានខ្ញុំគិតពិចារណាវែងឆ្ងាយ បានខ្ញុំសុខចិត្តរៀនគ្រូសារនៅឆ្នាំ ១៩៨៥ ខែ៧នឹង ។

ធានី ៖ ពួមកដំបូង ដឹងថាម៉ាឡៃស្ថិតនៅក្នុងស្រុកអូរជ្រៅ?

សារឿន ៖ អត់ដឹងដែរ ទាល់តែសមាហរណកម្មបានដឹង ខ្ញុំអត់ដែរ ។

ធានី ៖ ម៉េចបានពូដឹង?

សារឿន ៖ ដឹងដោយសារខ្ញុំឆ្លងកាត់តំបន់នឹងទៅផ្ទះគ្រួសារខ្ញុំអ្នកស៊ីសាផុន ទៅលេងម្តាយក្មេងស្ងួរម៉ែ ។

ធានី ៖ គាត់អ្នកចាស់ដែរ?

សារឿន ៖ ម្តាយខ្ញុំគាត់អ្នកស្រុកកំណើតនៅនឹង ។

ធានី ៖ ម៉េចបានគាត់ស្គាល់?

សារឿន ៖ គាត់ដឹង ចុះគាត់មនុស្សចាស់ស្រុកនឹង គាត់ដឹងនឹងហើយចាស់ពីដើម ។

ធានី ៖ អត់ដឹងនៅក្នុងតំបន់អីទេ?

សារឿន ៖ អត់ដឹងទេ ដឹងស្រុកអូរជ្រៅហើយ ។

ធានី ៖ ឃុំនិមិត្ត អត់ដឹងតំបន់?

សារឿន ៖ អត់ ។

ធានី ៖ ហើយមានប្រជាជនរស់នៅដែរ?

សារឿន ៖ អត់ទេព្រៃសុទ្ធ បើចាប់ពីម៉ក់ហឹនគ្មានទេ ព្រៃសុទ្ធ គេហៅផ្លូវថៅកែយ៉ៃពីដើមគេដឹកឈើតាមនេះឯង ។

ធានី ៖ ផ្លូវណា?

សារឿន ៖ ផ្លូវថៅកែយ៉ៃផ្លូវ៥០២ដែលជាប់ក្នុងដែនទីនឹងឯង ដែលយកជាប់ក្នុងដែនទី សព្វថ្ងៃគ្មានរូបរាងទេ។ យើងមានដីចំការដីអី មិនច្រើនណាស់ ។

ធានី ៖ ម៉េចបានកកើតតំបន់ម៉ាឡៃនឹង អ្នកណាអ្នកផ្តួចផ្តើមកកើត?

សារឿន ៖ ពូអត់ដឹងដែរ បើនិយាយបកក្រោយទៅវិញ ម៉ាឡៃនឹងយើងកើតវាយូរណាស់មកហើយ ដែលពូត្រឡប់មកដល់ប៉ៃលិននឹងដំបូង គេមានមន្ទីរនៅនេះស្រេចហើយ ។

ធានី ៖ គេហៅមន្ទីរ១០២ហ្នឹង?

សារឿន ៖ បាទ! នៅ១០២ កន្លែងផ្ទះអ៊ំបូ(ស្វាយ បូ) កន្លែងមន្ទីរ១០២ហើយ ។

ធានី ៖ កន្លែងសារតាំង?

សារឿន ៖ សារតាំងនឹងធ្វើក្រោយ ពូបានធ្វើដែរកន្លែងសារតាំងនឹង ពូអ្នកកាប់ផ្តៅធ្វើទាំងអស់ ពូកងការពារនៅខាងក្រៅ ។

ធានី ៖ ពូអ្នកកងការពារនៅសារតាំងនឹងដែរ?

សារឿន ៖ ធ្វើកន្លែងនឹងធ្វើជូនព្រះមហាក្សត្រ យើងធ្វើកន្លែងទទួលភ្ញៀវ ដូចថាភ្ញៀវបរទេសមកទស្សនកិច្ច ឬក៏ប្រគល់សារតាំងជូនព្រះមហាក្សត្រ ។

ធានី ៖ មកនឹងទៅ?

សារឿន ៖ បាទ! មកនឹង ។

ធានី ៖ ចុះក្រៅពីព្រះមហាក្សត្រមានដូចថាកូនគាត់ ឬអ្នកណាផ្សេងទស្សនាហ៍មកលេង?

សារឿន ៖ មានតើ មានម្នាក់ មកធ្វើចលនាតស៊ូជួយលីគ្រាប់កូនរបស់មហាក្សត្រសុទ្ធតែម្តង ។

ធានី ៖ គាត់មកនឹងដែរ?

សារឿន ៖ ឈ្មោះ មិនមែនសីហមុនីទេ កាលនឹងឈ្មោះគេហៅសីហា ។

ធានី ៖ សីហាកូនទីប៉ុន្មាន?

សារឿន ៖ អាចប្អូនសីហមុនី ខ្ញុំឃើញរូបរាងលោកស្អាតណាស់ គេលេងក្នុងរឿងអីទេខ្ញុំមើល លោកដើរតួជាកាកបាទក្រហម ។ លោកមកនឹងរហូតដល់លោកមានជម្ងឺអាពាធរហូតដល់មរណភាពនៅបារាំង លោកនឹងហើយមកនៅជាមួយខ្ញុំ ។ តែខ្ញុំនៅនេះហៅតែសីហមុនីអឺ!សីហា ។ ហៅក្រៅគេមិនឲ្យហៅអីចឹងផង ។

ធានី ៖ គេឲ្យហៅម៉េចវិញ?

សារឿន ៖ ហៅប្អូនសីហា ហៅដូចមិត្តភ័ក្តធម្មតា មិនមែនព្រះមហាក្សត្រគាត់អត់ឲ្យនិយាយផង ។

ធានី ៖ ម៉េចគាត់មកនៅនឹង?

សារឿន ៖ មិនយល់ដែរ ខ្ញុំនៅកងការពារនឹង ស្រាប់តែគេប្រាប់ថាកូនស្តេចមកមួយ នៅកន្លែងអ៊ឹផុនសព្វថ្ងៃគាត់នៅចៅហ្វាវាំងនៅជាមួយព្រះមហាក្សត្រ ។

ធានី ៖ ស្អីគេផុន?

សារឿន ៖ ផុននឹងដឹងហៅស្អីទេ តានឹងនៅនេះគេហៅតាផុនៗ តែទៅនៅជាមួយស្តេចរាល់ថ្ងៃ ។

ធានី ៖ មិនមែនចៅហ្វាវាំងគង់សំអុល?

សារឿន ៖ មិនមែនទេ ចៅហ្វាវាំងគង់សំអុលឃើញហើយ មិនមែនទេ ពួកខ្ញុំនាំគ្នាហៅគាត់តាគោលិតព្រោះសែងមកដាក់កន្លែងនេះគោលិតព្រះកេះគាត់ សែងទម្លាក់គាត់នោះ ។ អីចឹងបានគាត់អត់ភ្លេចទេ ខំកសាងកន្លែងសារតាំងជាមួយពួកចាស់ៗហាត់ប្រាណ ជាមួយម៉ីស៊ីសែមគាត់ខំជួយកន្លែងនឹងឡើងវិញ ព្រោះគាត់នៅនេះគាត់កំសត់ ។

ធានី ៖ អ៊ឹផុនគាត់នៅនឹងដែរ?

សារឿន ៖ នោះផ្ទះគាត់នៅកន្លែងផ្ទះលោកឈាន ចិញ្ចឹមជ្រូកច្រើន ផ្ទះគាត់នៅនឹងពីដើម ។ យើងនិយាយឲ្យខ្លីមកយើងមានគ្រឹះរួចមកហើយដែលយើងមក ខ្ញុំអត់ដឹងអីទេតែមកដល់ឃើញ ។

ធានី ៖ មានសុខ ភាព មានអី?

សារឿន ៖ បងសុខ ភាព ខ្ញុំអត់ទាន់ស្គាល់ទេ កាលនោះមេបញ្ជាការខ្ញុំឈ្មោះ ឈឹម មុន្នីៗអភិបាលស្រុកខ្ញុំមុន ឥឡូវគាត់នៅសង្គមកិច្ចអតីតយុទ្ធជននិតិសម្បទាខេត្តបន្ទាយមានជ័យនេះឯង ។

ធានី ៖ ដំបូងឈឹម មុន្នីនឹងគាត់មេបញ្ជាការ?

សារឿន ៖ កងមេបញ្ជាការវរសេនាតូចខ្ញុំកកើតមុនគេ គឺលោកឈឹម មុន្នី ដែលខ្ញុំថាចូលក្រោយចេញពីបងហៀងនឹង មកនៅជាមួយឈឹម មុន្នីនេះឯង វរសេនាតូច៧០៣ ។

ធានី ៖ លោកឈឹម មុន្នីខាងវរសេនាតូច អ្នកណាធំជាងគាត់?

សារឿន ៖ កាលនោះបើយើងនិយាយទៅវរសេនាតូចៗហៅវរសេនាតូចឯករាជ្យ រាយការណ៍ជូនថ្នាក់លើត្រង់ៗ ។

ធានី ៖ មានតែគាត់មួយទេ ឬមួយអ្នកផ្សេងទៀត មានប៉ុន្មានវរៈ?

សារឿន ៖ ឈឹម មុន្នី ខ្ញុំចាំបានមានតែគាត់ម្នាក់ឯង ព្រោះគាត់តាមខ្ញុំរហូត ក្រៅពីនឹងរងៗគាត់ខ្ញុំអត់ដឹង ។

ធានី ៖ លោកសុខ ភាព គាត់ឡើងពេលណា?

សារឿន ៖ សុខ ភាពអង្គភាពផ្សេង កងផ្សេងគ្នា ។

ធានី ៖ ចុះអ្នកណាគេក្តាប់រួមធំ?

សារឿន ៖ រួម សុខ ភាព ក្រោយមករួម សុខ ភាព ។

ធានី ៖ ហើយបន្ទាប់ពីលើ សុខ ភាព មានអ្នកណាគេទៀត?

សារឿន ៖ ក្រៅពីលើសុខ ភាព មានតែអ៊ំនៅភ្នំពេញនឹងឯង អ៊ំវ៉ាន់ ។

ធានី ៖ អ៊ំប៉ុន្មាននាក់?

សារឿន ៖ អ៊ំវ៉ាន់ ម្នាក់ឯង អត់មានអ៊ំណាទៀត ។

ធានី ៖ ចុះអ៊ំវ៉ាន់នឹងគ្រប់គ្រងប៉ុន្មាន?

សារឿន ៖ គ្រប់គ្រងតំបន់១០៧ ។

ធានី ៖ តែតំបន់១០៧មួយ តំបន់ផ្សេងអត់?

សារឿន ៖ អត់ៗដឹង ។

ធានី ៖ ចុះពេលពូនៅប៉ៃលិន អត់ដឹងអ៊ំវ៉ាន់នៅនោះ?

សារឿន ៖ អត់ដឹងទេ អត់ទាំងដែលឃើញផង ។

ធានី ៖ មកនៅនេះ?

សារឿន ៖ ខ្ញុំឃើញគាត់នៅនេះ ។

ធានី :     អ៊ីវ៉ាន់ ឧស្សាហ៍ចេញចូលនឹងច្រើន?

សារឿន : គាត់ឧស្សាហ៍ចេញចូល ហើយគាត់បានអប់រំច្រើនពីការរស់ គាត់ឃើញខ្ញុំមានប្រពន្ធ គាត់ថាកូនក្មួយទាំងអស់ត្រូវចេះរកស៊ីហូបចុកតាមរយៈទីផ្សារ ឲ្យមានបុសមានគល់ គាត់អត់ឲ្យកូនចៅគាត់ក្រទេ ។ ហើយខ្ញុំនៅជាមួយ និយាយឲ្យខ្ញីម៉ាមាត់ខ្ញុំអត់ដែលស្លៀកពាក់ខោអាវរហែកគូថមួយទេ ខោអាវគាត់ឲ្យម៉ាស្អាត តាំងពីមិត្តនារីដូចគ្នាដែរ គាត់ផ្គត់ផ្គង់ម៉ាស្រឡាញ់តាំងពីបាតជើងដល់សក់ក្បាល ។

ធានី :     រហូតដល់ឆ្នាំប៉ុន្មានបានគាត់ឈប់ផ្គត់ផ្គង់វិញ?

សារឿន : និយាយរួមរហូតដល់សមាហរណ៍កម្ម ។

ធានី :     បានគាត់ឈប់ផ្គត់ផ្គង់?

សារឿន : ពេលនឹងយើងសមាហរណ៍ជាមួយរដ្ឋាភិបាល គាត់ក៏ដូចគ្នាដែរ ។

ធានី :     ពូថានៅ៩១ធ្វើការជាអ៊ុនតាក់នឹងនៅមន្ទល ម៉េចបានពូនៅធ្វើការនៅនឹង?

សារឿន : កាលនឹងខ្ញុំទាហានមិញ ក្រោយមកយើងមានកិច្ចចរចាមួយជាមួយរដ្ឋាភិបាល កាលនោះត្រីភាគី យើងទៅចរចានៅទីក្រុងប៉ារីស ត្រូវមិនត្រូវខ្ញុំមិនដឹងទេ ប៉ុន្តែពួកខ្ញុំខាងក្រោមយើងមានគោលគំនិតមួយយើងគិតថា បើយើងអត់ចរចាគ្នាសមរភូមិទល់មុខ យើងអាចបាញ់គ្នាម្ល៉េះហើយខ្មែរនឹងខ្មែរ ខ្ញុំអត់ខ្ញុំអត់ចង់សម្លាប់គ្នាឯងទេ ។ ពួកខ្ញុំទាំងអស់គ្នាទាហានខាងក្នុងនិងខាងក្រៅ រដ្ឋកម្ពុជា និងកងទ័ពព្រៃយើងនឹង យើងចរចាគ្នារហូតដល់យើងទៅជួបUN ។ តែយើងទៅដល់UNលែងបាញ់គ្នាហើយ ខ្ញុំចរចាបានរយៈពេលប៉ុន្មានខែ ខ្ញុំចុះទៅធ្វើការនៅនឹងដោយមេបញ្ជាការរង ភី ភួន ហៅចៀម គាត់ឲ្យខ្ញុំទៅធ្វើការនៅនឹងរហូតដល់យើងមានកាន់បិណ្ឌកាន់អីជាមួយប្រជាពលរដ្ឋនៅក្នុងភូមិនឹង យើងធ្វើការនឹងដើម្បីយើងកុំឲ្យបាញ់គ្នា ហើយអ៊ុនតាក់វាមកសម្របសម្រួល វាបើកឡានមកព្រៃ មកកន្លែងខ្ញុំមក ។

ធានី :     ភី ភួននឹង អ៊ំចៀមនឹងគាត់ជាមេបញ្ជាការអីទេ?

សារឿន : រងកងពល ។

ធានី :     កងពល?

សារឿន : កងពល៨០៥ ។

ធានី :     បន្ទាប់ពីលោក សុខ ភាពមក គាត់?

សារឿន : គាត់ខាងសេដ្ឋកិច្ចដូចជម្រាបជូន គាត់ភស្តុភារទេ ។ តែគ្នាចូលចិត្តទៅមុខជាមួយយើង គាត់នៅអន្លុងវែងដឹកជញ្ជូន ។

ធានី :     ជាមួយពូជុំគ្នា?

សារឿន ៖ បាទ! ហូបអាហារ ។

ធានី ៖ កាលពេលពូនៅកន្លែងអ៊ុនតាក់នឹង នៅធ្វើអីគេនៅមង្គលបូរី?

សារឿន ៖ នៅធ្វើការងារផ្នែកយើងដែរ ការនឹងបើនិយាយធម្មតាគេដាក់ក្នុងផ្លាកដៃ គេដាក់ថាប៉ូលីសរបស់UNនឹងដែរ ដូចថាគេខាងរដ្ឋកម្ពុជា ខ្ញុំក៏មានបូលីស ។

ធានី ៖ ហើយយើងធ្វើអី?

សារឿន ៖ ធ្វើដើម្បីយើងចរចាប្រជាពលរដ្ឋឆ្លងកាត់ទៅវិញទៅមក អត់មានប៉ះពាល់អីគ្នា ។ យើងមានការត្រួតពិនិត្យច្បាស់លាស់របស់យើង ហើយអ្នកឯងយកអាវុធចូលស្រុកក៏អត់បានដែរ ។

ធានី ៖ ពូប្រចាំនៅស្រុកមង្គលបូរី ប្រចាំកន្លែងណាច្រកវា?

សារឿន ៖ ខ្ញុំនៅឃុំសឿ ។

ធានី ៖ កន្លែងនឹងផ្លូវចេញចូល?

សារឿន ៖ ច្រករបស់ខ្ញុំ ចេញពីបឹងកណ្តាលស្រះតាឈុននឹងទៅ ចំឃុំសឿ ខ្ញុំឡើងទៅមង្គលបូរីមក តែខ្ញុំខ្ទនឯងផ្ទាល់ដេកនៅភូមិតាមៅ ឃុំសឿ ដេកនៅធ្វើការ ។ បើនិយាយសម័យនោះ ខ្ញុំមិនជម្រាបជូនបានទេ ប៉ុនថាខ្ញុំមានទិសដៅផ្សេង ខ្ញុំចង់បង្រួបបង្រួមខ្មែរទាំងអស់មិនឲ្យបាញ់គ្នា ដោយគេជម្រើសយកយើងអ្នកគ្រាន់បើដែរទៅធ្វើការក្នុងនឹង ។

ធានី ៖ គេឲ្យធ្វើការតែពូ និងរដ្ឋកម្ពុជា តែ២បក្សនៅក្បែរគ្នា?

សារឿន ៖ បាទ! នៅជាមួយគ្នា ដេកនៅជាមួយគ្នាបានពួក២នាក់នឹង តែពួកខ្លាឃ្មោកអត់បានទេ ។

ធានី ៖ ខ្លាឃ្មោក ពួកណា?

សារឿន ៖ ប៉ាភ៉ា ។

ធានី ៖ មានប៉ាភ៉ាដែរ?

សារឿន ៖ មាន ។

ធានី ៖ នៅកន្លែងពូមានប៉ាភ៉ាៗខាងណា?

សារឿន ៖ មានទាំងអស់គ្នា ប៉ាភ៉ាខាងសីន សាន ខាងនរោត្តមរណឫទ្ធិក៏មាន ។

ធានី ៖ គេហៅប៉ាភ៉ា?

សារឿន ៖ ហៅប៉ាភ៉ាម៉ាមុខ តែមានជំរុំខុសគ្នា អាខ្លះនងចាន់ អាខ្លះជំរុំអំពិល ជំរុំថ្មី ។ ខ្ញុំប៉ាភ៉ារូបថតមួយគំណរនៅជាមួយគ្នា ។

ធានី ៖ មានរូបថតដែរ?

សារឿន ៖ មាន ។

ធានី ៖ មាននៅសល់?

សារឿន ៖ ទេ! មិនដឹងនៅត្រង់ណា ប៉ាភ៉ារូបខ្ញុំមើលអត់សូវច្បាស់ទៅហើយរូបវាយូរពេក ។

ធានី ៖ ចង់មើលប៉ាភ៉ា?

សារឿន ៖ ប៉ាភ៉ាវាសព្វថ្ងៃលែងស្គាល់គ្នាអស់វាចាស់ៗ ។

ធានី ៖ បន្ទាប់មកពូធ្វើអនុបញ្ញាការវរសេនាតូចនៅឆ្នាំប៉ុន្មាន?

សារឿន ៖ នៅ៩៣ ចេញពីបោះឆ្នោតមកវិញ ។

ធានី ៖ កាលនឹងពូបានបោះឆ្នោត?

សារឿន ៖ អត់ទេ ។

ធានី ៖ ម៉េចអីចឹង?

សារឿន ៖ យើងអត់ត្រូវគ្នា ។

ធានី ៖ អត់មានឈ្មោះគ្នា?

សារឿន ៖ មកវិញបាញ់គ្នាដូចព្យុះ មកវិញដាក់គ្នា កាំភ្លើងតូច កាំភ្លើងធំវៃគ្នារហូតដល់ឆ្នាំសមាហរណកម្មនិយាយឲ្យខ្លីវៃគ្នារហូត ។

ធានី ៖ ចុះប៉ាភ៉ាទៅណាបាត់?

សារឿន ៖ ប៉ាភ៉ាក៏នៅជាមួយយើង ។

ធានី ៖ ប៉ាភ៉ារួមសហការជាមួយយើង?

សារឿន ៖ ប៉ាភ៉ាគេចូល គេបានត្រឹកាគឺបោះឆ្នោតហើយ ប៉ាភ៉ាវាស្គាល់កន្លែងពួកខ្ញុំទាំងអស់ ។ វានាំមកវិញ វាបាញ់កាំភ្លើងគ្មានឲ្យខុសទេ ។ ខ្ញុំត្រូវដូរទីតាំងថ្មីអត់មានឯងដឹងទេ អាទីតាំងចាស់ខ្ញុំអត់នៅទេ ព្រោះកងទ័ពព្រៃចល័តស្ងាត់រស់រវើក គឺគេអត់ឲ្យលំនឹងដើររបស់គេដាក់មីនចោលហើយ ។ កម្លាំងខ្ញុំតិចទេ តែកម្លាំង៣០នាក់ ខ្ញុំនៅដេកនឹង១០ៗរហូត ។

ធានី ៖ ដាក់វាយគ្នា?

សារឿន ៖ បាទ! តែយប់ឡើងអត់មាននៅនឹងទេ ខ្ញុំដុតតែភ្លើងចោលខ្ញុំទៅដេកក្នុងព្រៃដុង ។ ក្មួយស្រីមក បាញ់កន្លែងខ្ញុំ ខ្ញុំព្លុខ្ញុំត្រៀមបាញ់ក្មួយឯង ។ បើពូនិយាយថាដល់ភាសាបច្ចេកទេសវាពិបាកស្តាប់ណាស់ ព្រោះកងទ័ពព្រៃក្មួយត្រូវគិតថាគេមានតែអង្រឹងមួយ ហើយនឹងសាក់ការដូរដូចក្មួយស្រីស្ពាយអីចឹង ខោអាវគេស្បៀងគេក្នុងនៃ រួចចង្ក្រានបាយ ឆ្នាំងបាយមានគ្រប់ ហើយតំបន់ណាដែលមានទឹកគេចល័តហើយ ។ ហើយបើយើងអត់ច្បាស់ក្នុងផែនទីយើងមិនដឹងថានៅកន្លែងណាមានទឹកញាំទេ ។

ធានី ៖ ពូថាកន្លែងមានទឹក អត់ទឹកមើលផែនទីម៉េច?

សារឿន ៖ តំបន់នឹង កាលណាមើលក្នុងដែនទីដូនញ៉ែម ដែនទីភាគខាងលិចប្រទេស ដែនទីវៀតណាម ខ្ញុំវ៉ៃទីតាំងវៀតណាមមួយ នៅឃុំចំណោម ខ្ញុំវ៉ៃបានដែនទីនឹងមួយ ខ្ញុំយកមកសិក្សាវាដោយ ខ្ញុំមិនមានជំនាញដែនទីច្បាស់ទេ តែអាចដឹងបានច្រើន ។ ខ្ញុំមើលដែនទីកន្លែងនេះមានស្រះទឹក ។ ចាក់ត្រីវិស័យទៅរកឃើញទឹកមែន ។ តែមានទឹក ធ្វើស្រែនឹងទឹក ធ្វើសឹកនឹងបាយ បើយើងអត់មានទឹកហូប យើងរស់អត់កងទ័ពខ្ញុំត្រូវតែមានទឹកមានអាហារបរិបូរអត់មានឲ្យអ្នកឯងអន់កម្លាំងបានទេ តែគ្មានចាញ់ខ្ញុំយកមកដេកពេទ្យ ។

ធានី ៖ ពូទៅកន្លែងណាមានទឹក បានពូចាប់ផ្ដើមធ្វើកន្លែងរស់នៅ?

សារឿន ៖ បាទ! ធ្វើជាកន្លែងរស់នៅ ធ្វើជាផ្ទះខ្ទមតូចៗទទឹង២បណ្ដោយ៤ម៉ែត្រ ។

ធានី ៖ បានសដែនទីវ៉ៃពេលណាដែរ?

សារឿន ៖ កាលនឹងនៅឆ្នាំ បានដែនទីដូច៩៨ វ៉ៃនៅឃុំចំណោម ។

ធានី ៖ ពូទើបបាន?

សារឿន ៖ ទើបបាន តែអាមុននឹងខ្ញុំមិនបាច់ដែនទី យើងមានអ្នកស្រុកប្រជាពលរដ្ឋអ្នកចាស់នៅនឹង គាត់មកបរបាញ់ក្នុងព្រៃ គាត់រកសត្វ ដឹងថានៅកន្លែងនេះមានបឹង យើងទៅតាមណាត់របស់គាត់អត់ខុសទេ ព្រោះអតីតភូមិចាស់របស់គេ ។ ដល់យើងសង្គ្រាមតាំងពីទសវត្ស ។

ធានី ៖ ៩៨បានដែនទីពីវៀតណាម?

សារឿន ៖ ពីវៀតណាម ។

ធានី ៖ នៅវ៉ៃគ្នាដែរ វៀតណាមនៅវ៉ៃនឹងដែរ?

សារឿន ៖ វៀតណាមអត់មានទេ មានតែកងទ័ពខ្មែរទេ ។

ធានី ៖ ម៉េចបានពូបានដែនទីនឹងមក?

សារឿន ៖ ដែនទីនឹងវៀតណាមចេញទៅ វាមិនទុកដែនទីទុក មិនកងទ័ពខ្មែរយើងយកមកសិក្សា មានអក្សរកម្ពុជាផង អក្សរវៀតណាមផង ។ ហើយគេដាក់ខាងលើគេដាក់ដែនទីដូនញ៉ែម ដែនទីនឹង ខ្ញុំយកសម្រាប់ធ្វើសឹករបស់ខ្ញុំសម្រាប់ចល័តតាមព្រៃតំបន់ណាដែលខ្ញុំអាចយល់បាន ហើយក្រៅពីនឹងមានមួយទៀតដែនទីគូដោយដៃខ្លួនឯងវាស់វែងតាមប្រជាពលរដ្ឋប្រាប់បឹង យើងចេះចាក់រកទៅ ។

ធានី ៖ ហើយត្រូវ?

សារឿន ៖ បាទ!ភាគច្រើនយើងមានជំនាញក្នុងព្រៃ ។

ធានី ៖ រាល់ថ្ងៃគាត់នៅរស់ទេ អ្នកជំនាញព្រៃ?

សារឿន ៖ ស្លាប់ហើយ ឈ្មោះអ៊ំជីង១ គាត់អាយុក្រោមសម្ដេចតាតែ៣ឆ្នាំ ។

ធានី ៖ គាត់ចាស់ហើយ?

សារឿន ៖ ចាស់ហើយ តែគាត់នៅតែរករបរព្រៃទាំងអស់ ។

ធានី ៖ គាត់ជំនាញព្រៃ?

សារឿន ៖ បាទ!ជំនាញព្រៃណាស់ គាត់អត់មានរើសអីទេ គាត់មកបាញ់សត្វ «ពុកអើយ!មកសម្រាក កន្លែងខ្ញុំមក» «កូនថាបើងត្រង់នេះមាន កូនឯងចង់ទៅត្រង់នោះ ជូនពុកទៅ» ខ្ញុំមានអេស្តូប ខ្ញុំ៥នាក់ ឲ្យដើរតាមដើម្បីបានសត្វមកញាំខ្លួនឯងដើម្បីចិញ្ចឹមទាហានខ្ញុំនឹងហើយ ។

ធានី ៖ គាត់ដឹងកន្លែងណាមានសត្វទៀត?

សារឿន ៖ ដឹងទាំងអស់ ។ តែគាត់ស្លាប់ហើយអំដឹងចាស់ក្រោមសម្តេចតា ។

ធានី ៖ គាត់ស្លាប់យូរនៅ?

សារឿន ៖ ស្លាប់យូរហើយ ខ្ញុំអត់បានទៅបុណ្យគាត់ ។

ធានី ៖ តាំងពីពេលណាទៅ?

សារឿន ៖ អត់ដឹងដែរ គ្រាន់ដឹងថាស្លាប់ ។

ធានី ៖ មិនមែនស្រុលយើងនេះ?

សារឿន ៖ ស្រុកយើងនៅស្រុកគាត់អន្តរបូរី(មន្តលបូរី) នៅសឿ គាត់ឈឺចាស់ ។

ធានី ៖ នៅស្រុកយើងលែងមានអ្នកដើរព្រៃទៀត?

សារឿន ៖ គ្មានទេ ដូចមេនេះនឹង នៅនឹងសុទ្ធតែប៉ះហើយព្រៃ ខ្ញុំសុទ្ធតែប៉ះព្រៃម្តុំនេះខ្ញុំមិនដែលស្គាល់ណា ។ ខ្ញុំនៅកំពតហេតុអីបានខ្ញុំដើរមកដល់តំបន់ម៉ាឡៃនេះបាន អាស្រ័យលើផែនទីនេះឯង

ធានី ៖ ពូមើលផែនទីដំបូង បានដើរដល់នេះ?

សារឿន ៖ បើនិយាយសរុបឲ្យខ្ញុំដើរតាំងពី៧៩ចេញមកពីភ្នំពេញមក យើងមើលផែនទីរហូត យើងមានផែនទីរបស់យើង ផែនទីប្រទេសកម្ពុជាយើង ។

ធានី ៖ ពូយកមកពីណាវិញ?

សារឿន ៖ ផែនទីខ្ញុំយកមកពីភ្នំពេញទៅ ខ្ញុំចេះកាន់ៗទុកវាលេង តែកាលជំនាន់នឹងមិនចាប់អារម្មណ៍ថាអីផង ព្រោះមនុស្សចូលចិត្តសិក្សា ខ្ញុំដកលើសៀវភៅចេះយកវាទុកទៅ ។

ធានី ៖ ពូខស្សាហ៍មើលសៀវភៅ?

សារឿន ៖ បាទ!

ធានី ៖ ធ្លាប់ឃើញទស្សនាវដ្តីបដិវត្ត ទស្សនាវដ្តីទង់ជាតិក្រហម?

សារឿន ៖ បាទ! អានឹងពូស្គាល់ច្បាស់ ។

ធានី ៖ ពូខស្សាហ៍មើលដែរ?

សារឿន ៖ មើល មិនមើលរាល់១ថ្ងៃទេ មើលមាត្រចាំបាច់ ។

ធានី ៖ ពូមាននៅសល់ទេ?

សារឿន ៖ អត់មាននៅសល់ទេ បាត់អស់ហើយ ។ មែនទែនថាមកដល់ស្រុកម៉ាឡៃយើងនេះ មកដល់គេហៅម៉ាឡាយភាសាសៀម ខ្មែរយើងអត់ដឹងហៅអីទេ ហៅម៉ាឡៃ ម៉ាឡាយហៅសេះបង្កង ។

ធានី ៖ ម៉េចគេហៅសេះបង្កង?

សារឿន ៖ សេះបង្កងវាមាននៅក្នុងភ្នំនេះ(ភ្នំម៉ាឡៃ)ពីដើមជំនាន់សៀមវាធ្វើប្រមាញ់សត្វ ។

ធានី ៖ មានសេះបង្កង?

សារឿន ៖ មានសេះបង្កងហៅដូចលា វាមាននៅនឹងសៀមវាថាដាក់ភ្នំម៉ាឡាយរហូត ។

ធានី ៖ ពូថានៅឆ្នាំ៩៦ ខែសីហា ថ្ងៃ១៥?

សារឿន ៖ ១៥ ។

ធានី ៖ មិនមែន៩៧?

សារឿន ៖ មិនមែន៩៧ទេ ពិតជា៩៦មែន ។

ធានី ៖ ហើយកាលនឹងមានអ្នកណាគេខ្លះមកពេលធ្វើសមាហរណកម្ម?

សារឿន ៖ សមាហរណកម្មមានសម្តេចតេជោ លោកអញ្ជើញមក ហើយមានគណៈរដ្ឋមន្ត្រីផ្សេងទៀតមានច្រើនណាស់ កំប៉ុកកំប៉ែងមកលេងមិនដឹងប៉ុន្មានថ្ងៃ បានគាត់អញ្ជើញមកបំពាក់ខោអាវមាននរោត្តមរណឫទ្ធិ ។

ធានី ៖ គាត់អញ្ជើញមកដែរ?

សារឿន ៖ មកដែរ មកមុនគេ តេជោគេមកក្រោយគេ តែគាត់ដឹងថាកម្លាំងរបស់គាត់ទៅហើយពួកខ្ញុំ

ធានី ៖ ពេលគាត់មកបំពាក់ឲ្យពូដែរ?

សារឿន ៖ អត់ទេ គាត់គ្រាន់មកដល់យើងប្តូរខោអាវយើងចេញ យើងពាក់ជាខោអាវយុទ្ធពលខេមរភូមិន្ទដូចមួកនេះពូបង្ហាញក្មួយស្រេច ។ មួកនេះនៅពេលស្លៀកពាក់ខោអាវ គ្រាន់ថាពូមិនបានថតជាអនុស្សាវរីយ៍អីទេ ។ កាលនឹងពូមិនទាន់មានតំណែងអីទេ តំណែងជាអនុបញ្ជាការវរសេនាតូច ។

ធានី ៖ ដល់ពូធ្វើរហូតដល់ឆ្នាំ៩៩ បោះឆ្នោតបានពូដូរ?

សារឿន ៖ បាទ! ខ្ញុំធ្វើជានាយការិយាល័យទី១ដូចជម្រាបជូនក្មួយស្រីគ្រប់គ្រងទាហាន៣២០ ។

ធានី ៖ ទាហាននៅនេះ?

សារឿន ៖ បាទ! នៅក្នុងវរសេនាធំខ្ញុំ៣២០ ។

ធានី ៖ ពូអនុសេនាតូចការិយាល័យទី១?

សារឿន ៖ ការិយាល័យទី១ពូចាប់ពីពូធ្វើការ៩៧ ៩៨មក ហ្នឹងហើយ ការិយាល័យទី១ដែលពូគ្រប់គ្រង ។

ធានី ៖ ដល់ពេលក្រោយមកទៀតបានដូរទៅជា?

សារឿន ៖ បានដូរទៅក្រុមប្រឹក្សាឃុំ ។

ធានី ៖ តែពូថាទាហាន៣២០?

សារឿន ៖ ៣២០គេបំបែកកាត់ក្បាល កងទ័ពចូលកន្លែងនេះ កន្លែងនោះអស់ នៅកងពល៥១ក៏មានស្រុកបន្ទាយមានជ័យក៏មាន ។

ធានី ៖ បែកគ្នាអស់?

សារឿន ៖ បាទ! គេបែងចែកអស់ហើយ ពីមុនកម្លាំងយើងក្ដាប់មូលខ្លួនឯង ពីមុនខ្ញុំនៅកងពល២១ ។ អីចឹងហើយរឿងវាអីចឹង ។

ធានី ៖ ពូមានប្រាក់រឺត្រែតអីសម្រាប់ទាហាន?

សារឿន ៖ ប្រាក់ពិការ អានឹងប្រាក់សង្គមកិច្ច គេកាត់យើងរំសាយចេញពីយោធាមក ។

ធានី ៖ ពូរំសាយពីឆ្នាំណា?

សារឿន ៖ មួយឆ្នាំហើយ២០០៩ ។

ធានី ៖ ពូធ្វើក្រុមប្រឹក្សាឃុំផង ធ្វើទាហានផង?

សារឿន ៖ ធ្វើទាហានផង តែខ្ញុំឈរឈ្មោះនៅក្រសួងការពារជាតិខ្ញុំអត់មានជាន់គ្នាទេ ខ្ញុំឈរឈ្មោះចោល ។

ធានី ៖ ទើបឆ្នាំនេះចាប់ផ្ដើមធ្វើ?

សារឿន ៖ បាទ! ខ្ញុំធ្វើមែនទែន២អាណត្តិ ។ អាណត្តិទី១នៅឆ្នាំ២០០០ ខ្ញុំកាន់តំណែងជាក្រុមប្រឹក្សាឃុំម៉ាសារ ។ អាណត្តិក្រោយទៀត ខ្ញុំឈរម៉ាអាណត្តិឥឡូវជិតបានបោះវិញហើយ ។ ខ្ញុំទាហានដូចថាគេយកយើងទៅកាត់រំសាយដូចថាយើងមានពិការ ដោយគេឲ្យប្រាក់បំណាច់អីៗរដ្ឋាភិបាលប្រគល់ជូនប៉ុននេះៗ ។

ធានី ៖ កាលពេលពូរៀបគ្រួសារនៅជំរុំនឹង ពូមានរៀបជាពិធីដូចយើងសព្វថ្ងៃនឹង?

សារឿន ៖ ពូរៀបមាន និយាយសន្ទេះបដូនក្លួយស្រី ហើយយើងគួរតែពិចារណាទាំងអស់គ្នា ដោយសារខ្ញុំបាទ និងគ្រួសារខ្ញុំអត់មានឪពុកម្ដាយ យើងរៀបនៅនឹងយើងពឹងពាក់អ្នកជិតខាងធ្វើជាម្ដាយឪពុក យើងមានរៀបមង្គលការខ្វះតែភ្លេង ហើយនឹងភ្លួងទេ ។

ធានី ៖ ក្រៅពីនឹងមានទាំងអស់?

សារឿន ៈ មានទាំងអស់ កំប្លេដូចគេដូចឯង មានស៊ីស្វាស៊ីម្ល មានស្ដីដណ្ដឹងពីវគ្គមួយរហូតដល់វគ្គ៣ រហូតដល់យើងរៀបការ មិនមែនចាប់ដៃទេ ។

ធានី ៈ ចុះពូមានរូបថតនៅសល់ទេ?

សារឿន ៈ អូ! រូបថតរលួយអស់ កាលនឹងជូនម្ដាយក្មេករលាយទឹកអស់ ។

ធានី ៈ អត់មានទុកខ្លួនឯងឲ្យកូនមើលទេ?

សារឿន ៈ អត់ទេ បើមាននៅសព្វថ្ងៃប្រហែលជាអាចឲ្យកូនបញ្ចូលក្នុងកុំព្យូទ័រវា ស្ដាយណាស់ប្អូនស្រី ខ្ញុំវាអត់ចេះទុក ខ្ញុំទៅរកមើលអត់ឃើញទេ ខ្ញុំផ្ញើទៅអាមេរិចកុងនឹងមួយ ហើយកុងខ្ញុំក៏មរណភាពបាត់ចប់ អត់មានហ៊ីលនៅទេ ។ អាពាហ៍ពិពាហ៍កំសត់ណាស់ យកផ្កាស្រស់មកដោយធ្វើក្នុងប្រពន្ធខ្ញុំ ។

ធានី ៈ ចុះពូកាលឆ្នាំ៩០ជាង ចន្លោះ៩២ ៩៣ ធ្លាប់មានពួកគេប្រមូលទ្រព្យសម្បត្តិឯកជនចូលរួមទេនៅម៉ាឡៃ?

សារឿន ៈ ម៉ាឡៃអត់មានដូចនេះទេ វាមានបញ្ហានឹង ។

ធានី ៈ វាផ្ដើម តែអត់បានធ្វើ?

សារឿន ៈ បាទ! មាន គេចង់ប្រមូល ទីបញ្ចប់ ។ មុនដំបូងគេប្រមូលឡានៗហើយម៉ូតូ កង់ រទេះគោអស់ យើងមានការតស៊ូបណ្ដោយ អានេះរឿងពិត ។ ឲ្យអស់ហើយ នៅប្រមូលទាំងរទេះគោ មិនកើតទេ ក៏នាំគ្នា ប៉ុនមិននឹងទៀត ពួកខ្ញុំដឹងថាដកម៉ាស៊ីនអារឈើ ដករទេះគោ ខ្ញុំមានអីស៊ី ច្បាំងផង សេដ្ឋកិច្ចគ្រប់គ្រងខ្លួនឯងផង ។ ចុះយើងត្រូវការមើល យើងត្រូវការម្សៅទឹកដោះគោក្នុងឃ្លាំងអត់ខ្វះទេ តែករណីចាំបាច់ខ្វះយើងត្រូវប្រើប្រាស់លុយ ។

ធានី ៈ ក្រោយទៅម៉េចបានឈប់?

សារឿន ៈ ឈប់ដោយសារ មិនមែនឈប់ទេ គេបន្តធ្វើរហូត ប៉ុនមេបញ្ជាការលោកមិនធ្វើ បងសុខភាព និងបងអ៊ី ឈាន គាត់អត់ធ្វើ ។

ធានី ៈ លោកអ៊ី ឈាន គាត់មកដល់នឹងដែរ?

សារឿន ៈ អត់ទេ គាត់ទាក់ទងតាមTelphone ពួកខ្ញុំទាក់ទងតែពីរក្រុមនឹង ។

ធានី ៈ តាកន?

សារឿន ៈ កណ្ដាលអត់ទេ គេកុម្មុយនីសរឹងណាស់ គេដឹកពេញសិទ្ធិ ។

ធានី ៈ តាកនគាត់ដកដែរ?

សារឿន ៈ គាត់ដកទាំងអស់អត់មានសល់អី ។

ធានី ៈ ដល់ពេលខាង?

សារឿន ៖ ខាងម៉ាខ្មែរ ហើយនឹងប៉ៃលិនអត់បានធ្វើ ។

ធានី ៖ អ្នកណាអ្នកផ្ដើមគំនិតឲ្យប្រមូល?

សារឿន ៖ មិនដឹងរឿងដែល គ្រាន់គេហៅខ្ញុំក្នុងឋានៈមេបញ្ជាការគេហៅទៅរៀនដើម្បីគេលាងខួរក្បាល យើងឲ្យជ្រះស្រឡះ ។ តែពេលនឹងពូអត់ជ្រះទេ ពូគិតថាតែដកនឹងអស់ហើយ មកដល់យើង អត់អនុវត្តតាម ។ បានន័យថាយើងប្រឆាំងហើយ យើងប្រឆាំងឲ្យដល់ទិសដៅ បើយើង អត់ប្រឆាំងឲ្យដល់ទិសដៅយើងអត់មានខ្លួនយើងទៅអត់រួច ។ ដល់ហើយយើងទៅអែបជា មួយរដ្ឋាភិបាល យើងមានកម្លាំង យើងមានសាច់ដុំ បើយើងអត់កើតហើយ ។

ធានី ៖ ពូឆ្លងកាត់២-៣ជំនាន់?

សារឿន ៖ ពូឆ្លងកាត់៣ជំនាន់ពេញ ។

ធានី ៖ ពូគិតថាជំនាន់ទាំង៣នឹង មើលទៅជំនាន់នឹងវាខុសគ្នាយ៉ាងម៉េចពីជំនាន់មួយទៅជំនាន់មួយ?

សារឿន ៖ សង្គមលន់ នល់ពិបាកម៉ាបែបសង្គ្រាមជាមួយលន់ នល់ ខ្មែរគ្នាឯង ។ កាល៣ឆ្នាំ៨ខែ២០ ថ្ងៃ អានឹងអត់បាយប្រជាពលរដ្ឋ តែខ្ញុំហូបឆ្អែត ។

ធានី ៖ ម៉េចបើពូដឹងថាអត់បាយ បើពូហូបឆ្អែត?

សារឿន ៖ ខ្ញុំហូបឆ្អែត ខ្ញុំដឹងដំណឹងកាលនោះ ខ្ញុំបើកឡានទៅដឹកខ្សាច់ ដឹកទៅធ្វើសំណង់ ដែលខ្ញុំនៅកង ចល័តធ្វើទាំងអស់សំណង់ ។ មកដល់ឃើញពលរដ្ឋនៅសហករណ៍អត់មានអីញ៉ាំទេ មានបបរ ខ្លះ ខ្ញុំនឹកឃើញក្នុងចិត្តនិយាយជាមួយបងជាតិខ្ញុំថា “បងជាតិអើយ! នេះខ្ញុំមានខោអាវ២ ការុង”ខោអាវ២បាវ ហើយខោទ្រនាប់ក្មេងស្រីលីអូ ខ្ញុំមាន២ការុងដែរ ហើយអាវទ្រនាប់ ២ការុង ហើយខោអាវកូនក្មេងក៏ដាក់ឡានសេអ៊ីមសេទៅដល់ខេត្តស្ទឹ សហករណ៍មួយនៅ ជិតរោងចក្រកំពង់ត្រាំនឹង ក៏ខ្ញុំឲ្យខោអាវសហករណ៍នឹង ឃើញសហករណ៍នឹងញ៉ាំបាយ ដូច ឃើញយើងដើរឆ្លងកាត់ជិតផ្លូវ គេឲ្យយើងស្អាតណាស់ គេមើលទៅបាយ ។ ហូបបាយ មែន តែពេលល្ងាចបបរ ។ ខ្ញុំស៊ើបៗគេ ប៉ុនយើងមិនហ៊ាននិយាយយ៉ាងម៉េចទេ ក្នុងពេល សម័យនោះ យើងពិបាកនិយាយ ដោយសារកន្លែងមួយៗខុសគ្នា ។ ក្រោយមក ពូធ្វើ ដំណើរទៅដឹកខ្សាច់ពូដាក់ទឹកកកឲ្យញ៉ាំទៀត ។ កន្លែងពូអត់ខ្វះអីញ៉ាំទេ ដឹកទឹកកកម្ដង៤-៥ ដើម ដឹកបង្កប់តាមអង្កាមនឹង យកទៅដាក់ឲ្យសហករណ៍នឹង គាត់ក៏ឲ្យទឹកត្នោតយើងញ៉ាំ ព្រោះយើងអ្នកក្រុងចូលចិត្តផ្អែមណាស់នៅអូរឪមនឹង ខ្ញុំមក អីចឹងខ្ញុំគិតថាពេលនឹង ខ្ញុំដឹង គេអត់បាយតាមរយៈខ្ញុំឃើញនឹងភ្នែកនឹង ។

ធានី ៖ ឆ្នាំប៉ុន្មានកាលនឹង?

សារឿន ៖ ឆ្នាំ១៩៧៦ ៧៧ ។ ៧៧កុំនិយាយ៧៦ ៧៧ចំតែម្ដងព្រោះ៧៧កាលនោះ ។

ធានី ៖ ពេលពួយកឲ្យពូអត់ខ្លាចគេ?

សារឿន ៖ អត់ទេ ប្រធានសហករណ៍គេអត់អីផង គេគាំទ្រយើង ។

ធានី ៖ ចុះម៉េចបានគេអត់បាយអត់អី?

សារឿន ៖ បាទ! ខ្ញុំអត់បានសួរទេ កន្លែងហ្នឹងពួយល់អត់ដល់ គិតថាស្រូវស្រុកនឹងធ្វើអត់កើតទៅចុះគ្នាយាប់ដែរ ។ ពេលធ្វើដំណើរទៅកំពុងសោម ផាកមើលខាងឆ្វេងដៃ ឥឡូវនេះគេមានបច្ចេកទេសដាំដុះខ្លាចវាអាចល្អ កន្លែងនោះស៊ីងខ្សាច់សុទ្ធជិតរោងចក្រ ធ្វើអត់កើតមែន ហើយតំបន់នឹងទឹកលិច ។

ធានី ៖ តែភ្លៀងខ្លាំងទឹកលិច?

សារឿន ៖ ម៉ាសហករណ៍នឹង គាត់នៅជាប់នឹង ម្លោះហើយគាត់មានការខ្វះខាត ។

ធានី ៖ នៅស្រុកអីគេ?

សារឿន ៖ ស្រុកគង់ពិសី មិនដឹងស្រុកអីដឹងខ្ញុំអត់ចាំច្បាស់ ។ ហើយសហករណ៍នឹងទៀតសោត ខ្ញុំមុនដំបូងខ្ញុំទៅលេង ទៅរកទឹកញ៉ាំ គេដាក់ទឹកក្តៅមានបំពង់ទឹកក្តៅត្រឹមត្រូវ នឹកឃើញថាកូនក្មេងច្រើន សល់អាវពីភ្នំពេញ ក៏ដាក់លើមាត់ឡានមក ។ យ៉ាងហោចណាស់ក៏បានជូនមិត្តនារី តែអត់ហ៊ានលើកទេ កាលជំនាន់នឹងយើងមានការអៀនខ្មាស់ ។ យើងមានការខ្ចប់វេចស្អាតទៅ យកទៅឲ្យពុកម្តាយចាស់ៗ ជំនាន់នឹងគេចូលចិត្តហៅម៉ែពុក "ថាម៉ែហា៎!ពុកហា៎! ខ្ញុំជូនខោអាវប៉ុននេះ អានេះខាងខ្ញុំៗខាងនេះ" ក៏យើងរៀបរយជូនគាត់ទៅ គាត់ក៏អបអរសាទរ ។

ធានី ៖ ពូឲ្យទៅប្រជាជនផ្ទាល់ ឬឲ្យទៅសហករណ៍?

សារឿន ៖ ផ្ទាល់ ប្រធានសហករណ៍នៅនឹងក៏អត់អី ល្អ ។

ធានី ៖ ស្គាល់ឈ្មោះគាត់ទេ កាលនឹងប្រធានសហករណ៍?

សារឿន ៖ ក្អួយអើយ! មិនចាំមិនបានសួរគេផង មិនចាប់ភ្លឹក ព្រោះយើង ពូនិយាយឲ្យខ្លី រូបពូពីក្មេងប្រលើមបន្តិចដែរ វាស្អាតដែរ ម្លោះហើយមិនសូវឲ្យគេឃើញប៉ុន្មានទេ ។

ធានី ៖ អៀនដែរ?

សារឿន ៖ អៀនដែរ បើកតែទ្វារឡានហើយៗ ។

ធានី ៖ កាលនឹងពូទៅតែម្នាក់ឯងទេ?

សារឿន ៖ ក្រុមខ្ញុំមាន៤នាក់ ឯកភាពគ្នាខោអាវរើសតាមផ្ទះមកទេ ។

ធានី ៖ ដែលថារើ រៀបសំអាតនឹង?

សារឿន ៖ បាទ! រៀបសំអាត ឃើញខោអាវស្អាតៗញាត់ទុក នឹកឃើញថាប្រជាពលរដ្ឋខ្វះខាត សហករណ៍នឹង ឃើញហើយ ឃើញ៣លើកហើយ បានយកសម្រេចលើកទី២សួរមេ សួរប្រធានខ្ញុំ ។

ធានី ៖ សួរតាៗ?

សារឿន ៖ ជាតិ ប៉ុនគាត់ស្លាប់ហើយ *"ជាតិហា៎!អញគិតយកខោអាវជូនសហករណ៍"* *"ហេ៎!សួរគេសិន"* ហើយយើងយកជូនគាត់ៗស្វាគមន៍មិនថាអីផង តាំងពីចៅសង្កាត់តាមខ្ញុំយល់ តែយើងអត់ស្គាល់គេផង ។ តែបើប្រធានសហករណ៍ច្បាស់ តែអត់បានសួរឈ្មោះ គ្រាន់ទៅដល់ជូនខោអាវហើយ ក៏ជូនទឹកកកហើយៗ ។ កន្លែងនោះភ្ញៀវកន្លែងចេញចូលដឹកខ្សាច់ចិនអី ។ ខ្ញុំចេញចូលហូបទឹក ។

ធានី ៖ ពូខស្សាហ៍ដឹកខ្សាច់នៅនឹង?

សារឿន ៖ ដឹកខ្សាច់ដើម្បីយកធ្វើសំណង់ជួសជុលកន្លែងបែកបាក់?

ធានី ៖ ការនឹងទៅជួសជុលនៅណាវិញ?

សារឿន ៖ នៅខ្ញុំដឹកខ្សាច់ដាក់នៅស្ថានទូតទួលទំពូង ស្ថានទូតចិនទួលទំពូង ខ្ញុំនៅកន្លែងនឹងម៉ាកន្លែងទៀត

ធានី ៖ ពូនៅនឹងដែរ?

សារឿន ៖ បាទ! នៅធ្វើកម្មករជួយធ្វើស្ថានទូតចិន អាងទឹកនៅក្រោយខ្ញុំធ្វើ ធ្វើក្នុងអាងខ្ញុំអ្នកធ្វើ ។

ធានី ៖ ចេះធ្វើសំណង់ទៀត?

សារឿន ៖ ខ្ញុំផ្នែកអគ្គីសនី ។ មិត្តភ័ក្តខ្ញុំនៅនេះ ពិការជើងស្តាំដូចខ្ញុំដែរ គាត់ជាជាងឈើ ផ្នែកគ្នាខ្ញុំផ្នែកអគ្គីសនីសុទ្ធ ។

ធានី ៖ ពូចេះភ្លើងច្រើន?

សារឿន ៖ បាទ! ចេះច្រើន ។

ធានី ៖ ចេះពីពេលណា?

សារឿន ៖ ចេះតាំងពីសម័យខ្ញុំរៀនជាមួយចិន ។

ធានី ៖ រៀនជាមួយចិនឆ្នាំណា?

សារឿន ៖ ចិនឆ្នាំ៧៦ ៧៧ ។

ធានី ៖ ៧៦រៀនទៀត?

សារឿន ៖ បាទ! ខ្ញុំចេញពីនឹងបានខ្ញុំទៅក-៧ ។ វានឹកអត់ឃើញដែរវាយូរពេក ។

ធានី ៖ រៀនពីណាគេចិននឹង ស្គាល់ឈ្មោះគាត់ទេ?

សារឿន ៖ ឈ្មោះ តាហ៊ូ ឡោ ហ៊ូ ។ ពិបាកនិយាយចិន ។

ធានី ៖ គាត់នឹងជាងអគ្គីសនី?

សារឿន ៖ ជាងអគ្គីសនី ។

ធានី ៖ កាលនឹងរៀនប៉ុន្មាននាក់?

សារឿន ៖ តែម្នាក់ឯង ។

ធានី ៖ តែពូម្នាក់ឯង?

សារឿន ៖ ចុះខ្ញុំមុខងារជាមួយគាត់នឹង គាត់ជាងខាងអគ្គីសនី គាត់យកខ្ញុំដើរតាម បើខ្ញុំអត់ដើរតាម គាត់ទារខ្សែម៉េចកើត គាត់មិនបង្រៀនខ្ញុំ ។

ធានី ៖ បាន២នាក់គាត់?

សារឿន ៖ បាន២នាក់គាត់ គាត់បុកការងារស្ថានទូតគាត់ធ្វើដែរ ម៉្លេះហើយត្រូវតែមានខ្ញុំ បើអត់មានខ្ញុំ ។

ធានី ៖ ពូឡោ ហ្នឹង ជាជាងអគ្គីសនីនៅស្ថានទូតចិត?

សារឿន ៖ របស់ចិន គេមកពីស្រុកមកជួសជុលកន្លែងរោងភាពយន្តគេដែលមានការបែកបាក់ ខ្ញុំជាមួយគាត់នឹងអ្នកតភ្លើង ជាមួយគ្នាបើនិយាយឲ្យខ្ញុំកម្មករសុទ្ធ ប៉ុនកម្មករសម័យនោះយើងអត់ប្រាក់ខែទេ កម្មករបាយហូប ។

ធានី ៖ ប៉ុន្តែមានសិទ្ធិច្រើន?

សារឿន ៖ មិនមានសិទ្ធិអីច្រើនទេ គ្រាន់ថាខ្ញុំនៅជាមួយចិន ។

ធានី ៖ ពូនៅស្ថានទូតនឹងប៉ុន្មានខែ បានទៅក-៧?

សារឿន ៖ ម៉ាឆ្នាំ ៧៧ប្រុច ។

ធានី ៖ ចុះពូថាបោសសំអាត?

សារឿន ៖ បោសសំអាតនឹងចាប់ផ្ដើមពី៧៧នឹងដែរ ។

ធានី ៖ ចុះពូថាធ្វើសំណង់?

សារឿន ៖ សំណង់នឹងក៏ក្នុងនឹងដែរ ។

ធានី ៖ បោសសំអាតផង ធ្វើសំណង់ផង?

សារឿន ៖ បាទ!

ធានី ៖ ទៅជួសជុលស្ថានទូតនឹង?

សារឿន ៖ បាទ!

ធានី ៖ ពូនៅស្ថានទូតចិនភាគច្រើនជាងគេ ជាងកន្លែងផ្សេង?

សារឿន ៖ បាទ! ច្រើនជាងកន្លែងផ្សេង ។

ធានី ៖ ចុះពូខស្សាហ៍ឃើញធ្លាប់ឃើញប្រធានាធិបតី?

សារឿន ៖ អត់ទេ ដូ អេនឡាយអត់ទេ ម៉ៅសេទុងក៏អត់ដែរ ឃើញស្ថានទូតគេមកដូរផ្លាស់ៗ មក ដូរផ្លាស់រហូតដល់សម័យចិនធ្លាក់កាប៉ាល់ហោះ ខ្ញុំអ្នកដើររកក្ដាររកអីធ្វើមឈូស ។

ធានី ៖ ឆ្នាំប៉ុន្មាន?

សារឿន ៖ ចាំមិនបាន វែងឆ្ងាយណាស់ ។

ធានី ៖ ធ្លាក់ៗ ?

សារឿន ៖ ធ្លាក់គាត់បង្រៀនខ្មែរយើងបើកបរ តែយន្តហោះនឹងវាខូចៗស្លាបជាងខ្មែរមិនឲ្យឡើងដែរ តែគាត់វាមិនអី ដល់ឡើងបានពាក់កណ្ដាលមិនគាំងឆេះធ្លាក់នៅអូរឌីមនេះ ។

ធានី ៖ នៅអូរឌីម?

សារឿន ៖ បាទ! ស្លាប់បាត់ ។

ធានី ៖ គាត់នឹង?

សារឿន ៖ មេៗជាងកាប៉ាល់ហោះ ។

ធានី ៖ ឆ្នាំប៉ុន្មានកាលនឹង?

សារឿន ៖ ពូមិនចាំ កាលនឹងដូច៧៨ ដូចខែ១១ ។ ៧៨ តាសាំង?

តាសាំង ៖ ហ្នឹងហើយ ៧៨ ។

ធានី ៖ កាលនឹងម៉េចបានគាត់បើកធ្លាក់?

សារឿន ៖ យន្តហោះវាខូច វាគាំងកន្លាល វាឆេះម៉ាស៊ីន ។

ធានី ៖ តែគាត់អ្នកបង្រៀនបើកយន្តហោះ?

សារឿន ៖ បាទ! គាត់គ្រូបង្រៀនខ្មែរយើង ។ ធម្មតាគាត់មេជាង គាត់ត្រូវឡើងតាមមេជាង គាត់ត្រូវឡើងតាមកូនជាងហើយ គាត់សម្រាប់ដឹងរឿងកាប៉ាល់ហោះវាខូចអី ចិនបង្រៀន ។

ធានី ៖ ដល់ពេលធ្លាក់អីចឹង ចិនគេអត់រករឿង?

សារឿន ៖ អត់ទេ គាត់មកបង្រៀនខ្លួនឯង គាត់ររករឿងអីគាត់ ខ្មែរយើងស្លាប់អស់ដែរ ម៉ាយន្តហោះស្លាប់ទាំងអស់ ។

ធានី ៖ ប៉ុន្មាននាក់?

សារឿន ៖ យន្តហោះនឹងកាលនឹងដូចជាមាន៤នាក់ ។

ធានី ៖ ហើយកាលនឹងពូពូអីចឹងមានភ័យអីទេ?

សារឿន ៖ អត់ផង ជិះឡានបើឃើញឆេះហ៊ុយៗ ឈរមើលពីលើឡាន ។

ធានី ៖ ចុះពូថាវៃក្ដារធ្វើមឈូស?

សារឿន ៖ ឈើក្តារនឹង ពូរកក្តារល្អៗដើម្បីជូន បើយើងនិយាយថាយើងលើកមុខលើកមាត់គេៗមកស្រុកយើង រកក្តារនាងនួនដើម្បីធ្វើប្រអប់ដាក់ឆ្អឹងទៅស្រុកគាត់ៗ ហើយកន្លែងនឹង ខ្ញុំដាងជាមួយចិនតាហូ ខ្ញុំដាងអគ្គីសនី តែតាហូនិយាយថាមានឈើត្រង់ណា គាត់អត់និយាយភាសាខ្មែរទេៗ

ធានី ៖ ពូចេះចិនដែរ?

សារឿន ៖ មិនអាចប្រាប់ក្មួយបានទេ គ្រាន់ថាខ្ញុំអត់ចេះទេ តែអាចស្តាប់បានៗ មិនចេះស្តាប់បាន តែគាត់សួរថា *"មានឈើនាងនួននៅណា?"* ខ្ញុំទៅរកជូនគាត់ល្មមម៉ាប្រអប់នឹងៗ ហើយគាត់យករូបនាគ វើសម្រាប់ដាក់ឆ្អឹងជនជាតិចិនយកទៅស្រុកចិនវិញ គាត់ទើបការប្រពន្ធហើយទៀតជនជាតិចិនៗ វែងឆ្ងាយ បើក្មួយសម្ភាសន៍ខ្ញុំ៣ម៉ោងក៏មិនចប់ផង ឆាកជីវិតខ្ញុំវាវែងណាស់ ដូចខ្ញុំរស់នៅជាកងចល័តៗ

ធានី ៖ ពូចល័តនៅបោសសំអាតផង នៅកន្លែងអគ្គីសនី?

សារឿន ៖ ដាងសំណង់បូករួមតែមួយ ពួកខ្ញុំគេឲ្យធ្វើកម្លាំងពាក្យថាចល័ត ឲ្យតែគេត្រូវការក្មួយឯងត្រូវការកម្លាំង៣០នាក់ មិនយកខ្ញុំទៅបាត់ កងខ្ញុំត្រៀមបម្រុងឲ្យគេប្រើ ត្រូវការតាសាំងគាត់ត្រូវការខ្ញុំប៉ុន្មាន៣០នាក់ ព្រោះកន្លែងគាត់បោសអត់ឈ្នះ យកទៅទៀតៗ

ធានី ៖ ចល័តនឹងគ្រប់កន្លែងដែលត្រូវការ?

សារឿន ៖ បាទ! ឲ្យត្រូវការខ្ញុំទៅៗ

ធានី ៖ ពូធ្វើការអីខ្លះទៅ បោសសំអាតផង ធ្វើជាងផង?

សារឿន ៖ ខ្ញុំផ្នែកខ្ញុំមែនទែនគេអត់សូវប្រើទេ ដល់ពេលនឹងខ្ញុំវាមានជំនាញម្យ៉ាង ប៉ុនពលកម្មខ្ញុំជួយក្រៅដូចជាមានការលើសែងបោសយើងធ្វើបាន បើការងារបច្ចេកទេស ខ្ញុំជាងអគ្គីសនីសុទ្ធខ្ញុំតភ្លើងដាក់តាមផ្ទះ ដូចថាបើអង្គការដាក់តាមមន្ទីរនេះមន្ទីរនោះទៅៗបើចាំបាច់ទេ ពួកខ្ញុំមានករណីពិសេសបើថាអត់ចាំខ្ញុំអត់ធ្វើទេៗ

ធានី ៖ កងរបស់ពូកងពិសេសជាងគេ?

សារឿន ៖ បាទ!

ធានី ៖ ពូព្យាបាលដែរ ពូធ្វើពេទ្យ?

សារឿន ៖ ខ្ញុំសុំលាក់ប្រវត្តិនឹងតិច ខ្ញុំពេទ្យពីដើមៗ

ធានី ៖ ពូធ្វើពេទ្យពីពេលណា?

សារឿន ៖ ខ្ញុំធ្វើតាំងពីឆ្នាំ១៩៧២ នារសាផង ពេទ្យផងៗ

ធានី ៖ ពូស្គាល់ជួន ជឿនទេ?

សារឿន ៖ ដួន ជឿន មេ ។

ធានី ៖ មេពេទ្យពូ?

សារឿន ៖ បាទន័យថាចេញ យើងនិយាយពីវិញ្ញាបនប័ត្រគាត់អ្នកចេញតែ តែរបបកម្ពុជាប្រជាធិប តេយ្យយើងអត់មានសញ្ញាប័ត្រអីពិតទេ ព្រោះយើងនៅព្រៃ ។

ធានី ៖ លោក តាដួន ជឿនមកជួយបង្រៀនពូដែរ?

សារឿន ៖ គាត់អត់មានបង្រៀនទេ មានគ្រូគេផ្សេង បងពឿនអ្នកបង្រៀន គាត់ស្លាប់អស់ហើយ ។

ធានី ៖ បងពឿននឹង គាត់នៅផ្នែកអីគេ បានមកបង្រៀនពូ?

សារឿន ៖ វះកាត់ ។

ធានី ៖ វះកាត់នៅមន្ទីរពេទ្យអីគេ?

សារឿន ៖ មន្ទីរពេទ្យ១៧មេសា ។ ខ្ញុំរៀនតាំងពីឆ្នាំ៧២ អត់មានទេ ខ្ញុំរៀននៅព្រៃស្រុកខាងខ្ញុំនោះ ។

ធានី ៖ ដល់ក្រោយ?

សារឿន ៖ ដល់ក្រោយខ្ញុំអត់មានធ្វើអីទេ ដែលខ្ញុំមកនៅភ្នំពេញ អត់ទេ គាត់អត់ដឹងថាខ្ញុំធ្វើពេទ្យ ។

ធានី ៖ ក្រោយ៧៩បានដឹង?

សារឿន ៖ បានដឹងថាខ្ញុំពេទ្យទេ ដល់មកមានមិត្តយើងរបួសៗមើលពេទ្យវាយឺតពេក ។

ធានី ៖ ឆ្នាំ៧៩?

សារឿន ៖ អត់ទេ ឆ្នាំ៨០ជាងបានខ្ញុំបង្ហាញមុខ ។

ធានី ៖ ថាពូធ្វើពេទ្យ?

សារឿន ៖ អត់ប្រាប់គេទៀត គ្រាន់អានភាសា ព្រោះថ្នាំពេទ្យមានភាសាបារាំងទាំងអស់ ក្នុយអត់ត្រូវទេ អានឹងយកមកចាក់នេះ អានេះថ្នាំជំនួយបេះដូងមិនអាចចាក់កន្លែងនេះបានទេ អានឹងថ្នាំជំនួយបេះដូង យើងយកមកចាក់កន្លែងនេះ ពេលណារបួសខ្សោយរបួសធ្ងន់ យើងយកមកចាក់ចេះ ហើយបានមិត្តនេះរបួសដាច់ជើងឈ្មោះ ផេង ពង្សវណ្ណថេង ខ្ញុំមើលពេទ្យវាយឺតពេក ខ្ញុំក៏ទាញសារ៉ាំរហូតបានបងជន មេបញ្ជាការឲ្យខ្ញុំកាន់ជាការសេនពេទ្យមួយធំសម្រាប់ឲ្យខ្ញុំធ្វើការវះកាត់ ។ ខ្ញុំកាត់ជើងអាមួយនៅជិតនេះ ខ្ញុំកាត់ជើងតែម្នាក់ឯងទេ កាត់ឆៅ ។ ហើយពេទ្យពួកខ្ញុំ កន្លែងណាក៏ខ្ញុំកាត់បានដែរ អត់ជំរើសទេ មានម៉ាស៊ីនមួយសម្រាប់កាត់ ម៉ាស៊ីនភ្លើង ។

ធានី ៖ ពូធ្វើពេទ្យផង ធ្វើជាអ្នកទូរលេខផង?

សារឿន ៖ មេបញ្ជាការផង ពេទ្យផង ។

ធានី ៖ មិនចាំបាច់មានពេទ្យគេតាម?

សារឿន ៖ មិនបាច់ទេ គឺពូខ្លួនឯងតែម្តង ។

ធានី ៖ ច្បាស់លាស់ល្អ?

សារឿន ៖ បាទ! ពេទ្យខ្លួនឯង ។

ធានី ៖ ដល់ឥឡូវនៅធ្វើពេទ្យ?

សារឿន ៖ ឥឡូវពូឈប់ហើយ ពូអត់ធ្វើទេ នៅផ្ទះនឹង គ្រាន់ថាតែកូនក្មួយខ្លួនឯងវាឈឺរោគរលាកប្រមុះនេះធំណាស់ ពូកំពុងព្យាបាលរោគនឹង ។ បើយើងនិយាយមានការប៉ះពាល់ច្រើន វាអាច allergyផង វាអាចកើតជាមហារីកក៏ថាបាន ព្រោះខ្ញុំអត់មានអីផ្ទុះទេ ។ ដែលខ្ញុំថាមិនពេទ្យពេលណា ដោយសារតែខ្ញុំអត់មានសញ្ញាប័ត្រ ។

ធានី ៖ ប៉ុន្តែពូបានរៀនចេះអស់ហើយ?

សារឿន ៖ ខ្ញុំបានសិក្សាច្រើន ជម្ងឺទូទៅខ្ញុំពូកែជាងគេ មានជំនាញទូទៅហើយវះកាត់បឋមចេះខ្លះ ។

ធានី ៖ ពូអត់មានបំណងចង់ធ្វើពេទ្យវិញ?

សារឿន ៖ អត់ទេ គសញ្ញាប័ត្រនៅភ្នំពេញថ្លៃ ។

ធានី ៖ នៅមណ្ឌលសុខភាពយើងគេអនុញ្ញាតិឲ្យយើង?

សារឿន ៖ អត់ទេ ពូអត់ចង់ៗ ពូចង់សព្វថ្ងៃត្រឹមរោគព្យាបាលជម្ងឺពោះវៀន ល្អ ។

ធានី ៖ ពូព្យាបាលខ្លួនឯង?

សារឿន ៖ បាទ!

ធានី ៖ ថ្នាំយើងឥឡូវ ឬថ្នាំបូរាណ?

សារឿន ៖ ថ្នាំយើងឥឡូវ បូរាណក៏ពូចេះខ្លះ បូរាណចេះច្រើនពាក់ព័ន្ធនឹងថ្នាំសរសៃ ថ្នាំកូនខ្ចីកូនប្រុសគឺកើតទាំងអស់ ។

ធានី ៖ បានពូអត់ព្រមទៅណា នៅពេលដែលកូនពូជិតគ្រប់ខែ?

សារឿន ៖ បាទ!

ធានី ៖ ពូធ្លាប់ឮពាក្យផ្សះផ្សា?

សារឿន ៖ អត់ដែលឮ ។

ធានី ៖ ផ្សះផ្សានឹងមានន័យថាធ្វើឲ្យត្រូវរូវគ្នា ចង់ធ្វើឲ្យត្រូវរូវគ្នាដូចថាចង់នៅជិត ឬនៅឆ្ងាយដើម្បីឲ្យគាត់ឆាប់ត្រូវរូវគ្នា?

សារឿន ៖ នៅឲ្យជិតមនុស្សម្នាក់នឹងដើម្បីយើងចង់ផ្សះផ្សាគេ ។

ធានី ៖ របៀបថាយើងនៅក្បែរគ្នាងាយជាង?

សារឿន ៖ ដើម្បីយកចិត្តគ្នា បើយើងតាមធម៌ព្រះគេនិយាយម៉ាបែប គេថាចង់ឈ្នះមនុស្សកំណាញ់ ត្រូវធ្វើទានឲ្យមនុស្សកំណាញ់ ភាសាបាលី ឱវាទព្រះពុទ្ធលោកថាអីចឹង ។

ធានី ៖ ពូចេះបាលីដែរ?

សារឿន ៖ តិចវស្សាដែរទេ ។

ធានី ៖ ពូបួសដែរ?

សារឿន ៖ ៥វស្សា ។

ធានី ៖ នៅណាវិញ?

សារឿន ៖ នៅវត្តខ្ញុំនៅ វត្តអង្គរជ័យ ។

ធានី ៖ ពូបួសឆ្នាំប៉ុន្មាន?

សារឿន ៖ ឆ្នាំ ៧០ នឹង ។

ធានី ៖ ពូបួសឆ្នាំ៧០ ៥វស្សា ពូចូល៧២?

សារឿន ៖ មិនដល់៧០ទេ ខ្ញុំបួស៧០នឹងឯង ដល់៥វស្សា ៧២ខ្ញុំធ្វើការតស៊ូបាត់ ។

ធានី ៖ ពូបួសបាន២វស្សា?

សារឿន ៖ ម៉ាវស្សាមានប៉ុន្មានខែៗ ៣ខែនឹង គិតទៅពូបួសបាន២ឆ្នាំពេញ ។

ធានី ៖ ២ឆ្នាំ?

សារឿន ៖ បាទ!

ធានី ៖ ពូអត់មានសល់រូបថតចាស់ ៨០ជាងអីមាននៅសល់?

សារឿន ៖ រូបថតពូពិបាកមើលតិច រូបថតទុកខ្លួនឯងសម្រាប់មើលខ្លួនឯង ។

ធានី ៖ រូបថតចេញពីទូរស័ព្ទ?

សារឿន ៖ ថតចេញពីរូបពូដែរ ។

ធានី ៖ ចុះរូបពូនៅផ្ទះមានទេ?

សារឿន ៖ មិនដឹងនៅណាទេ ។ នេះរូបពូកាលនឹងអាយុ៤៣ឆ្នាំ ។

ធានី ៖ អរគុណពូច្រើន ។

«ចប់»